UNODC
United Nations Office on Drugs and Crime

# ការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅ ក្នុងវិស័យធ្វើដំណើរនិងទេសចរណ៍ ការវិភាគក្របខ័ណ្ឌច្បាប់ជាតិ

## កម្ពុជា



ពង្រឹងក្របខ័ណ្ឌច្បាប់

2014

Australian Aid

UNODC United Nations Office on Drugs and Crime

# ប្រទេសកម្ពុជា

# ការប្រយុទ្ធប្រឆាំងការរំលោភបំពានផ្លូវភេទកុមារ
# ក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍

# របាយការណ៍ស្តីពីការវិភាគច្បាប់ និងការអនុវត្ត
# គម្រោងស្តីពីកុមារភាព
# (ផ្នែកកិច្ចការពារ)

ភ្នំពេញ

ឆ្នាំ២០១៤

# មាតិកា


សេចក្តីថ្លែងអំណរគុណ......5

អារម្ភកថាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ......7

អារម្ភកថាការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងឧក្រិដ្ឋកម្ម......9

សង្ខេប......11

អក្សរកាត់......13

១-សេចក្តីផ្តើម......15

២-វិសាលភាព......18

៣-ភាពមានកម្រិត......20

៤-ក្របខណ្ឌច្បាប់អន្តរជាតិ......21

៥-ក្របខ័ណ្ឌច្បាប់ប្រទេសកម្ពុជា......34

៦. ក្របខណ្ឌតំបន់......52

៧-ផែនការអនុវត្តន៍......56

# សេចក្ដីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបចំឡើង ក្រោមក្របខ័ណ្ឌរបស់គម្រោងស្ដីពីកុមារភាព។ គម្រោង ស្ដីពីកុមារភាព គឺជាការផ្ដួចផ្ដើមមួយរបស់ទីភ្នាក់ងារអូស្ត្រាលី ដែលមានទឹកប្រាក់ ៧.៥លានដុល្លារអូស្ត្រាលី ដើម្បីប្រយុទ្ធប្រឆាំងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងវិស័យធ្វើដំណើរ និងទេសសចរណ៍នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ គម្រោងកុមារភាពនេះពង្រឹងទៅលើកិច្ចគាំទ្រកម្មវិធីរយៈពេលវែងរបស់ប្រទេសអូស្ត្រាលី ក្នុងការការពារកុមារ និងទប់ស្កាត់អំពើរំលោភបំពានទៅលើពួកគេឲ្យបានកាន់តែប្រសើរឡើង។ គម្រោងកុមារភាពនេះមានការចូលរួមពី ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC), INTERPOL និងអង្គការទស្សនៈពិភពលោក (World Vision) ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍។ គម្រោងនេះអនុវត្តនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ គម្រោងនេះ ផ្ដោតទៅលើកិច្ចការពារ និងទប់ស្កាត់។

ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)

- សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ **លោកជំទាវ ខៀវ បូរី** អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងការដឹកនាំក្នុងការសម្របសម្រួលថ្នាក់ជាតិនៃដំណើរការពិគ្រោះយោបល់របាយការណ៍។
- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្ដម អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ដែលបានដឹកនាំកិច្ចពិភាក្សាក្នុងអំឡុងពេលពិគ្រោះយោបល់ និង ពិនិត្យរបាយការណ៍ឡើងវិញ។
- សូមថ្លែងអំណរគុណចំពោះ **លោកស្រី Lindsay Buckingham** ទីប្រឹក្សាឯករាជ្យរបស់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ប្រចាំតំបន់សម្រាប់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក សម្រាប់ការរៀបចំសេចក្ដីព្រាងរបាយការណ៍។ ក្នុងការរៀបចំ របាយការណ៍នេះ **លោកស្រី** បានទទួលការគាំទ្រដ៏មានតម្លៃពី **លោកស្រី Margaret Akullo** (អ្នកសម្របសម្រួលគម្រោងរបស់អង្គការ **UNODC** ប្រចាំតំបន់សម្រាប់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក) **លោកស្រី** Annethe Ahlenius (អ្នកសម្របសម្រួល **INTERPOL**) និង**លោកស្រី ចាន់ កញ្ញា** (មន្ត្រីគម្រោងថ្នាក់ជាតិរបស់អង្គការ UNODC ប្រចាំនៅកម្ពុជា)។

របាយការណ៍នេះ ត្រូវបានកែសម្រួលដើម្បីដាក់បញ្ចូលមតិយោបល់ពីក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ និងនគរបាលជាតិកម្ពុជា។ របាយការណ៍នេះត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

អង្គការ UNODC សូមថ្លែងអំណរគុណចំពោះកិច្ចគាំទ្ររបស់រដ្ឋាភិបាលនៃប្រទេស អូស្រ្តាលី។

## អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ កាលពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២ និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមចំនួនពីរនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ កាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០០២។ ការផ្តល់សច្ចាប័ននេះមានន័យថា ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្តជាផ្លូវការត្រូវតែគោរពសិទ្ធិកុមារ និងចាត់វិធានការនានាដើម្បីប្រែក្លាយខ្លឹមសារអនុសញ្ញានេះឱ្យទៅជាការអនុវត្តជាក់ស្តែង។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវការរីកចម្រើនលើគ្រប់វិស័យក្នុងនោះវិស័យសុខុមាលភាពកុមារមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ រាជរដ្ឋាភិបាល បានចាត់ទុកវិស័យទេសចរណ៍ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក្នុងនោះឧស្សាហកម្មទេសចរណ៍បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះចំណូលជាតិ និងបាន បង្កើតឱកាសការងារជាច្រើនដល់ប្រជាជនក្រីក្រ។ ទោះបីជាយ៉ាងណាក៏ដោយវិស័យទេសចរណ៍បាននាំ មកនូវផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនតូចនៅក្នុងសង្គមរបស់យើងផងដែរ។

ហេតុផលនៃការជួញដូរ និងការរំលោភបំពានកុមារ កើតមានជាញឹកញាប់គឺ ទាក់ទងទៅនឹងភាពក្រីក្រ។ ការរំលោភបំពានកុមារ ដោយជនល្មើសធ្វើដំណើរស្វែងរកផ្លូវភេទកុមារ គឺជាអំពើឧក្រិដ្ឋមួយប្រភេទដែលមានលក្ខណៈពិសេស ដោយសារតែជនល្មើសចល័តពីកន្លែងមួយទៅកន្លែងមួយ រួមទាំងការខ្វះកិច្ចសហការពីជនរងគ្រោះ និងគ្រួសារជនរងគ្រោះ និងល្បិចកលលួងលោមរបស់ជនល្មើស ដែលបទល្មើសប្រភេទនេះ បណ្តាលឱ្យមានបញ្ហាប្រឈមជាច្រើន ជាពិសេសសម្រាប់ស្ថាប័នអនុវត្តច្បាប់ដើម្បីផ្តល់យុត្តិធម៌ក្នុងសង្គម និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហារំលោភបំពានផ្លូវភេទលើកុមារ។

ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងអស់នេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) រួមជាមួយនឹងក្រសួងយុត្តិធម៌ និងសមាជិកមួយចំនួនរបស់ ក.ជ.ក បានសហការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) បានធ្វើការសិក្សាទៅលើក្របខណ្ឌ

ច្បាប់កម្ពុជា ដែលឆ្លុះបញ្ចាំងអំពីបទដ្ឋានអន្តរជាតិ ក្នុងការឆ្លើយតបយុត្តិធម៌ព្រហ្មទណ្ឌ លើបញ្ហាការរំលោភបំពានកុមារដោយជនល្មើសធ្វើដំណើរស្វែងរកផ្លូវភេទកុមារ។ ការសិក្សាកំនត់រកឱ្យឃើញនូវភាពខ្វះចន្លោះនៃច្បាប់នៅក្នុងប្រទេសកម្ពុជា និងផ្តល់នូវអនុសាសន៍មួយចំនួន សម្រាប់ធ្វើកំណែទម្រង់ច្បាប់ដើម្បីបំពេញ កង្វះចន្លោះទាំងនោះ និងផ្តល់នូវផែនការអនុវត្តអនុសាសន៍ច្បាស់លាស់សម្រាប់កំណែទម្រង់ច្បាប់ និងសកម្មភាពអនុវត្តដែលមានភាពជាក់លាក់សម្រាប់គំរោងកុមារភាព (ផ្នែកកិច្ចការពារ) ។

ជាមួយនឹងរបកគំហើញនៅក្នុងការសិក្សាខាងលើ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានដាក់បញ្ចូលអនុសាសន៍មួយចំនួន ទៅក្នុងរបាយការណ៍ជាតិវិភាគក្របខណ្ឌច្បាប់ ពាក់ព័ន្ធនឹងការការពារកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានជំនឿយ៉ាងមុតមាំថា លទ្ធផលនៃការសិក្សានេះនឹងក្លាយទៅជាឧបករណ៍មួយសម្រាប់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធទាំងឡាយយកទៅប្រើប្រាស់ជាប្រយោជន៍ប្រកបដោយប្រសិទ្ធភាព និងចំគោលដៅ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងសហការីដែលបានផ្តួចផ្តើមឱ្យមានការសិក្សាដ៏មានសារៈសំខាន់នេះ ហើយសង្ឃឹមថា លទ្ធផលនៃការសិក្សានេះ នឹងផ្តល់នូវ កាលានុវត្តភាពមួយដើម្បីអភិវឌ្ឍឱ្យមាននូវកិច្ចខិតខំប្រឹងប្រែង ដែលផ្តោតការយកចិត្តទុកដាក់ទៅលើ កំណែទម្រង់ច្បាប់ពាក់ព័ន្ធនឹងកិច្ចការពារ ការទប់ស្កាត់ និងការបង្ក្រាបអំពើជួញដូរកុមារ ទាំងនៅក្នុងប្រទេស និងតំបន់។

**ភ្នំពេញ, ថ្ងៃ១៥ ខែឧសភា ឆ្នាំ២០១៣**

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**អគ្គលេខាធិការ**

**ខៀវ មុរី**

## អារម្ភកថា ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម

នាទសវត្សចុងក្រោយ ឧស្សាហកម្មទេសចរណ៍ក្នុងប្រទេសកម្ពុជា កំពុងតែរីកលូតលាស់យ៉ាងខ្លាំង តែជាអកុសល ប្រទេសកម្ពុជាក៏ជាប្រទេស ដែលកំពុងតែក្លាយជាគោលដៅរបស់ពួកជនល្មើសស្វែងរកផ្លូវភេទលើកុមារដែរ និងការអភិវឌ្ឍន៍វិជ្ជមាននេះ ជារឿយៗត្រូវបានប្រែក្លាយជាការកើនឡើងនៃហានិភ័យដល់កុមារ ដែលរស់នៅតាមតំបន់ដែលមានកំនើនទេសចរណ៍ខ្ពស់។

កង្វះចន្លោះនៃច្បាប់ ធ្វើអោយជនល្មើសធ្វើដំណើរស្វែងរកផ្លូវភេទកុមារបានរួចខ្លួនពីការចាប់ខ្លួន និង ផ្តន្ទាទោស ហើយកុមារកាន់តែងាយរងគ្រោះ និងងាយស្រួលធ្វើទំនាក់ទំនងជាមួយដើម្បីធ្វើការកេងប្រវ័ញ្ច ដោយសារតែកំរិតនៃភាពក្រីក្រមានការកើនឡើងខ្ពស់ និងបណ្តាញសង្គមមានភាពទន់ខ្សោយ ។ហេតុដូច្នេះហើយបានជាគោលបំណងចំបងមួយក្នុងចំណោមគោលបំណងនានារបស់គម្រោង ស្តីពីកុមារភាព (ផ្នែកកិច្ចការពារ) គឺធ្វើការជាមួយដៃគូរជាមួយ រាជរដ្ឋាភិបាល ដើម្បីពង្រឹងក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ។

ការវិភាគនេះ ធ្វើការប្រៀបធៀប ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ កំនត់អំពីកង្វះចន្លោះនៃច្បាប់ និងបានផ្តល់អនុសាសន៍មួយចំនួន ក្នុងការពង្រឹងក្របខណ្ឌច្បាប់ សម្រាប់ការពារកុមារ។ របាយការណ៍នេះ និងបម្រើផលប្រយោជន៍ជាមូលដ្ឋានសម្រាប់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរកំណែទម្រង់ច្បាប់ ដើម្បីដោះស្រាយក្នុងការប្រយុទ្ធប្រឆាំងនឹងជនល្មើសធ្វើដំណើរស្វែងរកផ្លូវភេទលើកុមារ។

អ្វីដែលសំខាន់ គឺថារបាយការណ៍នេះ មានទម្រង់ជាការស្រាវជ្រាវដ៏ទូលំទូលាយនៅក្នុងបណ្តាប្រទេសទាំងបួន គម្រោងស្តីពីកុមារភាព។នៅក្នុងការប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងប្រទេសមួយ ការស្វែងយល់ពីធាតុពិតនៃការប្រព្រឹត្តបទល្មើសផ្លូវភេទលើកុមារឆ្លងដែនក្នុងវិស័យ

ទេសចរណ៍ គឺមានសារៈសំខាន់ណាស់ យើងត្រូវប្រាកដថា មិនបណ្តាលអោយមានការប៉ះពាល់ជាអវិជ្ជមានដល់ប្រទេសជិតខាងទេ។ ការជះឥទ្ធិពលនេះជារបាយការណ៍ធ្វើការពិភាក្សាអំពីមូលហេតុដែលធ្វើអោយមានផលវិបាកក្នុងការសហការឆ្លងកាត់ព្រំដែនដើម្បីធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសធ្វើដំណើរស្វែងរកផ្លូវភេទលើកុមារ។

ខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជារដ្ឋាភិបាលប្រទេសឡាវ ថៃ និងវៀតណាម មើលឃើញអំពីសារៈប្រយោជន៍នៃរបាយការណ៍នេះ ហើយនឹងប្រើប្រាស់ការវិភាគនេះដើម្បីពង្រឹងមូលដ្ឋានច្បាប់ការពារកុមារ។

ម្យ៉ាងទៀតខ្ញុំរីករាយខ្លាំងណាស់ ដែល UNODC សហការជាមួយ **INTERPOL** និង **World Vision** កំពុងបង្ហាញនូវការរីកចំរើនតាមរយៈគម្រោងស្តីពីកុមារភាព ដែលចូលរួមចំណែកធ្វើអោយបរិយាកាសកាន់តែមានសុវត្ថិភាពដល់កុមារនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។

**ភ្នំពេញ, ថ្ងៃ១៥ ខែឧសភា ឆ្នាំ២០១៣**



**Olivier Lermet**

ប្រធានគ្រប់គ្រងប្រចាំប្រទេស

ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងឧក្រិដ្ឋកម្ម (UNODC) កម្ពុជា

# សង្ខេប

របាយការណ៍នេះ ផ្ដល់នូវការវិភាគប្រៀបធៀបមួយទៅលើក្របខ័ណ្ឌច្បាប់ក្នុងស្រុក នៅក្នុងប្រទេសកម្ពុជា ដោយធៀបទៅនឹងបទដ្ឋានអន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ រាប់បញ្ចូលការកំណត់ចាត់ទុកថា ជាបទឧក្រិដ្ឋចំពោះការប្រព្រឹត្ត កិច្ចការពារកុមាររងគ្រោះ និងសាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងវិធានការសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ឆ្លងកាត់ព្រំដែន នៅក្នុងករណីទេសចរណ៍ផ្លូវភេទលើកុមារ។ របាយការណ៍នេះ ក៏ពិចារណាផងដែរទៅលើក្របខ័ណ្ឌថ្នាក់តំបន់ ដែលគាំទ្រកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន ដើម្បីស៊ើបអង្កេត និងផ្ដន្ទាទោសទៅលើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ និងកំណត់រកកាលានុវត្តភាពនានា ដើម្បីពង្រឹងក្របខ័ណ្ឌទាំងនោះ។ ដោយប្រើប្រាស់ការវិភាគនេះជាមូលដ្ឋាន របាយការណ៍បានផ្ដល់នូវអនុសាសន៍មួយចំនួនសម្រាប់កំណែទម្រង់ក្របខ័ណ្ឌច្បាប់ និងគូសបញ្ជាក់អំពីផែនការអនុវត្តន៍ ដើម្បីផ្ដល់ការណែនាំដល់សកម្មភាពជំនួយបច្ចេកទេសសំដៅគាំទ្រដល់កំណែទម្រង់ទាំងនោះ។

លទ្ធផលទាំងនេះផ្ដល់នូវកាលានុវត្តភាពមួយ ដើម្បីអភិវឌ្ឍអោយមាននូវកិច្ចខិតខំ ដែលផ្ដោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់ច្បាប់ ទាំងនៅក្នុងប្រទេស និងក្នុងតំបន់ ដែលស្របទៅនឹងសេចក្ដីត្រូវការរបស់ប្រទេសដៃគូ ភាពខ្វះចន្លោះនៃច្បាប់ ដែលមានលក្ខណៈជាក់លាក់ចំពោះប្រទេសនីមួយៗ និងតំបន់ទាំងមូល ព្រមទាំងបំពេញបន្ថែមទៅលើក្របខ័ណ្ឌច្បាប់ដែលមានស្រាប់។

ជាមួយនឹងកម្រងអភិក្រមច្បាប់ផ្សេងៗគ្នា សម្រាប់ដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ និងធ្វើដំណើរ ប្រទេសកម្ពុជាគឺជាទីកន្លែងដ៏សមរម្យសម្រាប់ចែករំលែកព័ត៌មាន និងបទពិសោធន៍នានាអំពីការអនុវត្តល្អ ដើម្បីអភិវឌ្ឍកំណែទម្រង់ដែលមានបច្ចុប្បន្ន ភាពជាក់ស្ដែង និងភាពស្របទៅនឹងច្បាប់របស់ប្រទេសជិតខាង។ របាយការណ៍នេះ ផ្ដល់វេទិកាមួយដើម្បីចាប់ផ្ដើម ការងារដ៏សំខាន់នេះនៅក្នុងប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍគោលដៅកម្មវិធីកំណែទម្រង់ ដែលពង្រឹង កិច្ចខិតខំរបស់រដ្ឋាភិបាលប្រទេសកម្ពុជា និងតំបន់ទាំងមូល សំដៅដោះស្រាយបញ្ហារំលោភបំពានផ្លូវភេទលើកុមារ ក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍។

**សំគាល់**:

សូមបញ្ជាក់ថាមានអង្គការខ្លះប្រើប្រយោគ "ជនល្មើសធ្វើដំណើរស្វែងរកផ្លូវភេទកុមារ" ឬ "ការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍" របាយការណ៍នេះនឹងប្រើប្រយោគ "ទេសចរណ៍ផ្លូវភេទកុមារ " ដើម្បីអោយត្រូវគ្នានឹងភាសាច្បាប់ដែលប្រើប្រាស់ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) និង ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការជួញដូរកុមារ អំពើពេស្យាចារលើកុមារ និង រូបភាពអាសអាភាសនៃកុមារ(២០០០)។

## អក្សរកាត់

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងស្ត្រី (១៩៧៩) |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) |
| CRC Optional Protocol | ពិធីសារបន្ថែមស្តីពីការលក់កុមារ អំពើពេស្យាចារលើកុមារ និងរូបភាពអាសអាភាសនៃកុមារ (២០០០) |
| ECPAT International | អង្គការបំបាត់ពេស្យាចារលើកុមារ រូបភាពអាសអាភាសកុមារ និងការជួញដូរផ្លូវភេទលើកុមារ |
| ICCPR | សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ (១៩៦៦) |
| ILO | អង្គការពលកម្មអន្តរជាតិ |
| ILO Convention 182 | អនុសញ្ញាស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សំរាប់ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ |
| INTERPOL | អង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ |
| Lao PDR | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ |
| MOU | អនុស្សរណៈនៃការយោគយល់ |
| NPA | ផែនការសកម្មភាពជាតិ |
| TIP | ការជួញដូរមនុស្ស |
| TIP Protocol | ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (២០០៥) |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| UNODC | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និង ឧក្រិដ្ឋកម្ម |
| UNTOC | អនុសញ្ញាសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនមានការគ្រោងទុក (២០០០) |

## ១-សេចក្តីផ្តើម

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរឹងមាំ គឺជាឧបករណ៍ដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងទៅនឹង ឧក្រិដ្ឋកម្ម។ ក្របខ័ណ្ឌយុត្តិធម៌ព្រហ្មទណ្ឌរឹងមាំមួយដែលឆ្លុះបញ្ចាំងអំពីបទដ្ឋានអន្តរជាតិសំខាន់ៗ និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅកម្រិតប្រទេស ជួយពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់ដើម្បីទប់ស្កាត់ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ [១] ។ នៅក្នុងប្រទេសកម្ពុជា ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ បង្កឱ្យមាននូវបញ្ហាប្រឈមមួយគួរឱ្យកត់សម្គាល់សម្រាប់មន្ត្រីអនុវត្តច្បាប់។ ជារឿយៗ ជនល្មើសមិនត្រូវបានសមត្ថកិច្ចរកឃើញឡើយ ដូច្នេះពួកគេកេងប្រវ័ញ្ចទៅលើកុមារដែលងាយរងគ្រោះបំផុត ហើយពួកគេត្រឡប់ទៅកាន់ប្រទេសរបស់ពួកគេ វិញដោយនិទណ្ឌភាព ឬក្នុងករណីដែលពួកគេរស់នៅយូរអង្វែងក្នុងប្រទេស ពួកគេនៅតែបន្តលាក់ខ្លួនក្នុងសហគមន៍។ ជាមួយនឹងការកើនឡើងនៃវិស័យទេសចរណ៍នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ បុរសដែលមកពីប្រទេសលោកខាងលិច ប្រហែលជាអ្នកទេសចរណ៍ផ្លូវភេទដែលគេអាចមើលឃើញច្បាស់ជាងគេបំផុត ដោយឡែកព័ត៌មានបង្ហាញឱ្យដឹងថា ជាក់ស្តែងតម្រូវការរបស់អ្នកដំណើរអាស៊ីក្នុងតំបន់តំណាងឱ្យជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារភាគច្រើន[២]។ ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ ពុំមែង តែងតែជាជនបរទេសឡើយ។ ទេសចរណ៍ផ្លូវភេទលើកុមារ ក៏រាប់បញ្ចូលជនល្មើសដែលធ្វើដំណើរនៅក្នុងព្រំដែននៃប្រទេសរបស់ពួកគេ ដែលកេងប្រវ័ញ្ចទៅលើផ្លូវភេទលើកុមារផងដែរ។ ប្រវត្តិរបស់ជនល្មើសអាចរាប់បញ្ចូលអ្នកធ្វើដំណើរឆ្លងកាត់ និងអ្នករស់នៅរយៈពេលវែង។

ទេសចរណ៍ផ្លូវភេទលើកុមារ គឺជាសកម្មភាពឧក្រិដ្ឋមួយប្រភេទដែលមានលក្ខណៈពិសេស ដែលបទល្មើសប្រភេទនេះក៏បណ្តាលឱ្យមានបញ្ហាប្រឈមនានា ជាពិសេសសម្រាប់ស្ថាប័នច្បាប់ និងស្ថាប័នយុត្តិធម៌ ក្នុងការអភិវឌ្ឍ និងអនុវត្តន៍សកម្មភាពឆ្លើយតបប្រកបដោយប្រសិទ្ធភាពផងដែរ។ លក្ខណៈពិសេសមួយដ៏សំខាន់នៃការប្រព្រឹត្តសកម្មភាពនេះ គឺជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ តែងតែទៅទស្សនាកន្លែងដែលពួកគេជាធម្មតាមិនធ្លាប់រស់នៅ និងប្រើប្រាស់ភាពអនាមិករបស់ពួកគេ ដើម្បីសម្រប

---

[១] ខណៈពេលដែលគេបានកត់សម្គាល់ថា អង្គការមួយចំនួនចូលចិត្តប្រើពាក្យ "ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ" ឬ "ការកេងប្រវ័ញ្ច ផ្លូវភេទលើកុមារនៅពេលធ្វើដំណើរ ឬទេសចរណ៍" របាយការណ៍នេះ នឹងប្រើប្រាស់ពាក្យ "ទេសចរណ៍ផ្លូវភេទលើកុមារ" ដើម្បីឱ្យមាន សង្គតភាពទៅនឹងវាក្យស័ព្ទបច្ចេកទេសច្បាប់ ដែលត្រូវបានប្រើប្រាស់នៅក្នុង *អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) និងពិធីសារបន្ថែមនៃអនុសញ្ញា នេះស្តីពីការជួញដូរកុមារ ពេស្យាចារលើកុមារ និងរូបភាពអាសអាភាសនៃកុមារ (២០០០)។*

[2]http://www.unicef.org/eapro/activities_3757.html

សម្រួលដល់ការប្រព្រឹត្តបទល្មើស។ នេះគឺជាការពិតសម្រាប់ជនល្មើសដែលបានរៀបចំផែនការសកម្មភាពរបស់ពួកគេ និង ជនល្មើសឆ្លៀតឱកាស (ដែលជាប្រភេទជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារទូទៅបំផុត)។ កន្លែងស្នាក់នៅ សេវាកម្មដឹកជញ្ជូន និងសេវាកម្មទេសចរណ៍ដទៃទៀត ជាពិសេសសេវាកម្មដែលបង្កលក្ខណៈឱ្យមានទំនាក់ទំនងជាមួយកុមារ ក៏អាចត្រូវបានប្រើប្រាស់ដោយជនល្មើសដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តបទល្មើសរបស់ពួកគេផងដែរ។ ជារឿយៗ សហគមន៍មិនស្គាល់ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារឡើយ ឬ ក្នុងករណីដែលពួកគេរស់នៅយូរអង្វែងនៅក្នុងប្រទេស ពួកគេអាចមានទំនាក់ទំនងបន្តិចបន្តួចប៉ុណ្ណោះជាមួយសហគមន៍។ ភាពអនាមិក និងភាពចល័តរបស់ពួកគេមានន័យថា ការឆ្លើយតបរបស់មន្ត្រីអនុវត្តន៍ច្បាប់ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានការសម្របសម្រួល ដើម្បីកាត់បន្ថយភាពខ្វះចន្លោះនៃច្បាប់ និងធានាថាព្រំដែនសមត្ថកិច្ចពុំមែនជាឧបសគ្គមួយដែលរាំងស្ទះដល់ដំណើរការផ្តន្ទាទោសឡើយ។

ក្នុងនាមជាភ្នាក់ងារអនុវត្តន៍ចម្បងនៃគម្រោងស្តីពីកុមារភាព (ផ្នែកកិច្ចការពារ) ការិយាល័យ អង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) កំពុងធ្វើការងារជាមួយដៃគូ អន្តរជាតិ និងដៃគូរដ្ឋាភិបាលនានា ដើម្បីអភិវឌ្ឍឱ្យមាននូវក្របខណ្ឌច្បាប់រឹងមាំ សំដៅកំណត់គោល ដៅទៅលើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងតំបន់។ គម្រោងនេះ ស្ថិតនៅក្រោមកម្មវិធី គម្រោងស្តីពីកុមារភាព ដែលមានលក្ខណៈទូលំទូលាយជាងនេះ (២០១០-២០១៤) ដែលទទួលបាន ជំនួយមូលនិធិគាំទ្រពី AusAID និងអនុវត្តនៅក្នុងប្រទេសដៃគូអាទិភាពចំនួន៤ រួមមានដូចជា កម្ពុជា ឡាវ ថៃ និង វៀតណាម ដែលបានអនុម័តជ្រើសរើសយកយុទ្ធសាស្ត្រសសរស្តម្ភចំនួនពីរ ដែលច្របាច់បញ្ចូលគ្នានូវកិច្ចការពារ និងការបង្ការទប់ស្កាត់។ តាមរយៈកិច្ចការពារអង្គការ UNODC ក្រោមភាពជាដៃគូជាមួយអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ (INTERPOL) មានគោលបំណងលើកកម្ពស់សមត្ថភាពអនុវត្តន៍ច្បាប់សម្រាប់សកម្មភាពជាតិ និងអន្តរជាតិ ដើម្បីកំណត់អត្តសញ្ញាណ និងធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាពទៅលើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ នៅក្នុងមហាអនុតំបន់មេគង្គ។ សសរស្តម្ភផ្នែកកិច្ចការពារ មានគោលបំណងផ្តល់នូវកញ្ចប់រួមមួយសម្រាប់ការកសាងសមត្ថភាពជូនដល់រដ្ឋា-ភិបាលនៃប្រទេសគោលដៅគម្រោង និង ភ្នាក់ងារអនុវត្តន៍ច្បាប់របស់ពួកគេតាមរយៈសមាសធាតុចំនួន ពីរគឺ៖ សមាសធាតុទី១ដែលដឹកនាំដោយអង្គការ UNODC នឹងផ្តោតទៅលើការផ្តល់សកម្មភាពជំនួយបច្ចេកទេសដែលឆ្លើយតបទៅនឹងភាពខ្វះចន្លោះ និងសេចក្តីត្រូវការសំខាន់ៗផ្នែកច្បាប់ ការបណ្តុះ-បណ្តាល និងកិច្ចសហប្រតិបត្តិការនៃប្រទេសដៃគូទាំង៤។ សមាសធាតុទី២ ដែលដឹកនាំដោយអង្គការ INTERPOL នឹងរួមមានសកម្មភាពប្រតិបត្តិការឯកទេសមានពេលវេលាកំណត់ ដែលមានគោលបំណងដាក់បញ្ចូលគ្នានូវធនធានស៊ើបអង្កេតកម្រិតអន្តរជាតិ និងតំបន់ ដើម្បីកំណត់គោលដៅឱ្យបានជាក់លាក់ទៅលើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ។ សសរស្តម្ភផ្នែកបង្ការទប់ស្កាត់ ត្រូវបានអនុវត្តដោយអង្គការ

ទស្សនៈពិភពលោក និងមានគោលបំណងពង្រឹងបរិយាកាសការពារសម្រាប់កុមារនៅក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ ដោយរាប់បញ្ចូលការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ និងការប្រឆាំងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ព្រមទាំងធ្វើការងារជាមួយរដ្ឋាភិបាល ដើម្បីអភិវឌ្ឍវិធានការជាតិដើម្បីធ្វើការទប់ស្កាត់ប្រកបដោយប្រសិទ្ធិភាព។

របាយការណ៍នេះ ផ្តោតការយកចិត្តទុកដាក់ទៅលើការងារដែលអង្គការ UNODC និង INTERPOL ត្រូវអនុវត្តក្រោមគម្រោងស្តីពីកុមារភាព (ផ្នែកកិច្ចការពារ) ជាពិសេសលទ្ធផលទី១ (ក្របខណ្ឌច្បាប់ទាក់ទង ទៅនឹងការបង្កើន និងអភិវឌ្ឍន៍ការប្រយុទ្ធប្រឆាំងទៅនឹងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ និងកិច្ចការពារជនរងគ្រោះ) និងធាតុចេញ ១.១ (ការត្រួតពិនិត្យឡើងវិញទៅលើច្បាប់) និងធាតុចេញ១.២(អនុសាសន៍នានាដែលបញ្ជាក់ច្បាស់ និងអាចអនុវត្តបាន ត្រូវបានដាក់ជូនដៃគូរាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍ក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ)[៣] ។ របាយការណ៍នេះផ្តោតសំខាន់ទៅលើក្របខណ្ឌច្បាប់ក្នុងស្រុក នៃប្រទេសកម្ពុជា និងបំពេញបន្ថែមទៅលើរបាយការណ៍ដែលមានលក្ខណៈស្រដៀងគ្នា ដែលត្រូវបានរៀបចំសម្រាប់ប្រទេសអនុវត្តគម្រោងស្តីពីកុមារភាព។ របាយការណ៍នេះ ត្រូវបានបង្កើតឡើងដោយមានការពិភាក្សាគ្នាជាមួយដៃគូជាតិ និងផ្តល់ជាវេទិកាមួយសម្រាប់អនុវត្តអនុសាសន៍ជាក់លាក់មួយចំនួន ដើម្បីពង្រឹងការឆ្លើយតបផ្នែកច្បាប់ទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា។

នៅប្រទេសកម្ពុជា គេអាចមើលឃើញយ៉ាងច្បាស់ថា មានការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់រដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ រាជរដ្ឋាភិបាល បានអភិវឌ្ឍច្បាប់ និងគោលនយោបាយ ដែលមានគោលបំណងការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ ផ្តន្ទាទោសទៅលើ ការប្រព្រឹត្តបទល្មើស និងលើកកម្ពស់សិទ្ធិរបស់កុមាររងគ្រោះ និងសាក្សី តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ វិធានការទាំងនេះ មានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងការរំលោភបំពានទៅលើកុមារ ដែលមានលក្ខណៈកាន់តែទូលំ ទូលាយជាងនេះ។ បើទោះជាដូច្នេះក្តី មានភាពខ្វះចន្លោះមួយចំនួននៅក្នុងក្របខណ្ឌច្បាប់ជាតិ និង ភាពគ្មានសង្គតភាពមួយចំនួន បើធៀបទៅនឹងវិសាលភាពនៃបទដ្ឋានអន្តរជាតិពាក់ព័ន្ធទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារដែលត្រូវបានអនុវត្តន៍។ ហានិភ័យគឺថា ខណៈពេលដែលនៅតែមានភាព ខ្វះចន្លោះនៃច្បាប់ ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជានឹង ស្វែងរកធ្វើការកេងប្រវ័ញ្ចទៅលើភាពខ្វះ

---

3 គម្រោងស្តីពីកុមារភាព ៖ កិច្ចការពារ ឯកសាររៀបចំគម្រោង

ចន្លោះទាំងនោះ ហើយពួកគេនឹងពុំមានការភ័យខ្លាចក្នុងការស្វែងរកធ្វើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារឡើយ។

លើសពីនេះទៀត ការឆ្លើយតបនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ មានសារៈសំខាន់ក្នុងការកសាងឱ្យមាននូវការរាំងស្ទះផ្លូវច្បាប់ចំពោះទេសចរណ៍ផ្លូវភេទលើកុមារ។ ក្របខណ្ឌច្បាប់ដែលមានភាពទន់ខ្សោយ អាចលើកទឹកចិត្តចំពោះតម្រូវការឱ្យមាននូវអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបង្កើនភាពងាយរងគ្រោះរបស់កុមារ ខណៈពេលដែលជនល្មើសកំណត់រកឃើញឱកាស ក្នុងការកេងប្រវ័ញ្ចទៅលើកុមារ ដែលហានិភ័យនៃសកម្មភាពរបស់ពួកគេអាចត្រូវបានរកឃើញមានកម្រិតទាបបំផុត [4]។ ដូច្នេះ ច្បាប់ជាតិដែលមានភាពតឹងរឹងដែលហាមឃាត់ ចំពោះបទល្មើសផ្លូវភេទលើកុមារ និងកំណត់ទោស ប្បញ្ញត្តិឱ្យបានធ្ងន់ធ្ងរ គឺ ជាឧបករណ៍សម្រាប់ទប់ស្កាត់ដ៏សំខាន់[5]។ បើទោះជាដូច្នេះក្តី ក្នុងករណីដែលប្រទេសមួយបានអភិវឌ្ឍឱ្យមាននូវក្របខ័ណ្ឌច្បាប់គ្រប់ជ្រុងជ្រោយ សម្រាប់ប្រឆាំងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ ទំនងនឹងងាកសកម្មភាពរបស់ពួកគេទៅកាន់ប្រទេសជិតខាង ដែលច្បាប់នៅក្នុងវិស័យនេះមិនសូវមានការអភិវឌ្ឍន៍ [6]។ ចំណុចនេះមានន័យថា ការឆ្លើយតបកម្រិតតំបន់មួយដែលមានការសម្របសម្រួល មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាថា ច្បាប់ជាតិត្រូវបានធ្វើសុខដុមរមនីយកម្មឱ្យមានភាពស្របគ្នា និងមានវិធានការសហប្រតិបត្តិការផ្នែកច្បាប់ ជាលក្ខណៈអន្តរជាតិ ទូលំទូលាយនៅក្នុងតំបន់ ដើម្បីឱ្យជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារគ្មានកន្លែងលាក់ខ្លួន។

## ២-វិសាលភាព

ឯកសារនេះ ពិចារណាទៅលើវិសាលភាពដែលប្រទេសកម្ពុជាអនុវត្តស្របតាមបទដ្ឋានច្បាប់អន្តរជាតិ ក្នុងការអភិវឌ្ឍឱ្យមាននូវការឆ្លើយតបពីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ។ ឯកសារនេះ កំណត់រកភាពខ្វះចន្លោះនៅក្នុងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ផ្តល់អនុសាសន៍ ទូលំទូលាយសម្រាប់វិស័យកំណែទម្រង់នានា ដើម្បីដោះស្រាយបញ្ហាខ្វះចន្លោះទាំងនោះ ព្រមទាំង គូសបញ្ជាក់អំពីផែនការអនុវត្តន៍មួយសម្រាប់សកម្មភាពជាក់លាក់ សំដៅអនុវត្តអនុសាសន៍ទាំងនោះ ក្រោមកម្មវិធីគម្រោងស្តីពីកុមារភាព (ផ្នែកកិច្ចការពារ)។

---

4 http://www.ecpat.net/worldcongressIII/PDF/Journals/EXTRATERRITORIAL_LAWS.pdf -- p4

5 Ibid.

6 http://www.ecpat.net/ei/Publications/CYP/YP_Guide_to_CST_ENG.pdf -- p8

ដើម្បីផ្ដល់នូវក្របខណ្ឌមួយប្រកបដោយសង្ខេបភាព សម្រាប់ធ្វើការប្រៀបធៀបច្បាប់របស់ប្រទេសកម្ពុជា ដែលអនុវត្តគម្រោងធៀបទៅនឹងកាតព្វកិច្ចអន្តរជាតិសំខាន់ៗ របាយការណ៍ពិចារណាទៅលើសំណួរដូចខាងក្រោម ៖

- **ស្ថានភាពនៃការផ្ដល់សច្ចាប័នទៅលើលិខិតុបករណ៍អន្តរជាតិសំខាន់ៗ ៖** តើប្រទេសកម្ពុជាបានចុះហត្ថលេខា ឬផ្ដល់សច្ចាប័នទៅលើលិខិតុបករណ៍ណាខ្លះ?
- **ការផ្ដន្ទាទោស និងទោសប្បញ្ញត្តិសម្រាប់ការប្រព្រឹត្តដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទ លើកុមារ៖** តើប្រទេសកម្ពុជា ផ្ដន្ទាទោសទៅលើការប្រព្រឹត្តដែលទាក់ទងទៅនឹងបទល្មើសទេស- ចរណ៍ផ្លូវភេទលើកុមារដែរឬទេ? តើទោសប្បញ្ញត្តិពាក់ព័ន្ធមានអ្វីខ្លះ?
- **វិធានការការពារកុមារនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ៖** តើមានវិធានការច្បាប់ ឬគោលនយោបាយសម្រាប់ការពារកុមាររងគ្រោះ និងសាក្សី នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុកដែរ ឬទេ?
- **វិធានការសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែន៖** តើបទល្មើសទេសចរណ៍ ផ្លូវភេទលើកុមារអាចធ្វើបត្យាប័នបានដែរឬទេ? តើច្បាប់របស់ប្រទេសកម្ពុជាបង្កើតឱ្យមាននូវអំណាចតុលាការក្រៅដែនដី សម្រាប់បទល្មើសទាំងនេះដែរឬទេ? តើមានលិខិតុបករណ៍អ្វីខ្លះ ដែលមានលក្ខណៈទូលំទូលាយជាងនេះ សម្រាប់ផ្ដល់ការណែនាំចំពោះកិច្ចសហប្រតិបត្តិការតំបន់ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ[7]?
- **កិច្ចសហប្រតិបត្តិការតាមតំបន់៖** តើមានក្របខ័ណ្ឌការងារអ្វីខ្លះ ដើម្បីសម្របសម្រួលដល់ កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ឆ្លងកាត់ព្រំដែនជាផ្លូវការ (ការធ្វើបត្យាប័ន និងការផ្ដល់ជំនួយឱ្យ គ្នាទៅវិញទៅមកនៅក្នុងបញ្ហាឧក្រិដ្ឋកម្ម) ជាមួយប្រទេសដទៃទៀតដែលអនុវត្តគម្រោង? តើមានលិខិតុបករណ៍ទូលំទូលាយអ្វីខ្លះ សម្រាប់ណែនាំដល់កិច្ចសហប្រតិបត្តិការតាមតំបន់ ដើម្បីប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ?

---

[7] ខណៈពេលដែលគេកត់សម្គាល់ថា បទដ្ឋានអន្តរជាតិដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ រាប់បញ្ចូលកាតព្វកិច្ចរបស់រដ្ឋ ដើម្បីធានាថា ទ្រព្យសម្បត្តិដែលទទួលបានពីការប្រព្រឹត្តបទល្មើស អាចត្រូវបានដកហូត និងរឹបអូស របាយការណ៍នេះ នឹងមិនពិចារណា ដោយផ្ទាល់ ទៅលើភាពអនុលោមរបស់ប្រទេស ចំពោះកាតព្វកិច្ចនេះឡើយ។ យន្តការសម្រាប់ការគ្រប់គ្រង ទៅលើទ្រព្យសម្បត្តិ

និងឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើសអាចមានភាពស្មុគស្មាញ ដូច្នេះ វិសាលភាពនៃរបាយការណ៍នេះ ពុំបានគ្របដណ្ដប់ទៅលើការវិភាគពេញលេញចំពោះយន្តការទាំងនេះនៅក្នុងប្រទេសដៃគូនីមួយៗឡើយ។

ក្របខណ្ឌនៃការស្រាវជ្រាវនេះ ត្រូវបានអនុម័តយ៉ាងខ្ជាប់ខ្ជួននៅក្នុងរបាយការណ៍រៀងខ្លួនសម្រាប់ប្រទេសអនុវត្តគម្រោងនីមួយៗ។

របាយការណ៍នេះ ត្រូវបានអភិវឌ្ឍក្នុងលក្ខណៈជាផ្នែកមួយនៃផែនការអនុវត្តន៍ដែលទូលំទូលាយជាងនេះ ក្រោមគម្រោងស្តីពីកុមារភាពរបស់ UNODC (ផ្នែកកិច្ចការពារ)។ អនុសាសន៍ និងសំណើសម្រាប់ការអនុវត្តដែលត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ មានបំណងបញ្ចូលទៅក្នុងផែនការគម្រោងដែលមានលក្ខណៈទូលំទូលាយជាងនេះ និងជាពិសេស គឺដើម្បីបំពេញបន្ថែមទៅលើសកម្មភាពរបស់ INTERPOL ក្រោមកិច្ចការពារ និងបំពេញបន្ថែមទៅលើសកម្មភាពរបស់អង្គការទស្សនៈពិភពលោក ក្រោមសសរស្តម្ភផ្នែកបង្ការទប់ស្កាត់។

កំនត់សម្គាល់ថា អង្គការ UNODC នឹងធ្វើការងារក្រោមភាពជាដៃគូជាមួយ INTERPOL ដើម្បីអនុវត្ត កិច្ចការពារ ហើយ INTERPOL នឹងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយភ្នាក់ងារអនុវត្តន៍ច្បាប់របស់ប្រទេសកម្ពុជា និងប្រទេសដៃគូនានា នៅក្នុងអាណត្តិការងារនេះ ដូច្នេះរបាយការណ៍ច្បាប់នេះមិនបានធ្វើការប៉ាន់ប្រមាណទៅលើវត្តមាននៃ កិច្ចសហប្រតិបត្តិការមិនផ្លូវការរបស់មន្ត្រីអនុវត្តន៍ច្បាប់ (ឧទាហរណ៍ ការចែករំលែកព័ត៌មានចារកម្មដោយ ផ្ទាល់រវាងភ្នាក់ងារនគរបាល) ក្នុងចំណោមវិធានការដទៃទៀតដែលមាន សម្រាប់ឆ្លើយតបទៅនឹងបញ្ហា ទេសចរណ៍ផ្លូវភេទលើកុមារឡើយ។ ដោយឡែក របាយការណ៍នេះផ្តោតការយកចិត្តទុកដាក់ទៅលើ យន្តការផ្លូវការ រវាងរដ្ឋាភិបាលសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់កម្រិតអន្តរជាតិ (ជាពិសេសការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក)។

## ៣-ភាពមានកម្រិត

ការស្រាវជ្រាវដែលបានធ្វើឡើង ដើម្បីរៀបចំរបាយការណ៍នេះ មានមូលដ្ឋានផ្អែកលើឯកសារច្បាប់ និងឯកសារគោលនយោបាយដែលមានជាភាសាអង់គ្លេស តាមរយៈការិយាល័យប្រចាំប្រទេសរបស់ UNODC នៅក្នុងប្រទេសកម្ពុជា និងឯកសារទទួលបានពីប្រភពអ៊ីនធឺណែត ដែលគួរឱ្យជឿជាក់បាន។ របាយការណ៍នេះ ក៏បានធ្វើការដកស្រង់ពីឯកសារពាក់ព័ន្ធមួយចំនួន ដែលបានផ្សព្វផ្សាយដោយភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានាលើបញ្ហា ទេសចរណ៍ផ្លូវភេទលើកុមារ និងបញ្ហាពាក់ព័ន្ធដទៃទៀត។

ខណៈពេលដែលឯកសារទាំងនេះ បានផ្តល់នូវព័ត៌មានប្រកបដោយ សារៈប្រយោជន៍ទៅតាមបរិបទផ្សេងៗគ្នាក៏ដោយ តែឯកសារជាច្រើនពុំមានបច្ចុប្បន្នភាព ឬផ្តោតទៅលើការដោះស្រាយ បញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅក្នុងបរិបទទូទៅជំនួសឱ្យការផ្តោតជាក់លាក់ទៅលើបញ្ហា ទេសចរណ៍ផ្លូវភេទលើកុមារ។ ផ្អែកលើបទពិសោធន៍ស្រាវជ្រាវរបាយការណ៍នេះ ការបន្តវិភាគ និងការផ្សព្វផ្សាយ ជាសារធារណៈពីឯកសារច្បាប់ និងការអនុវត្តច្បាប់ឆ្លើយតបទៅ នឹងបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ អាចជួយបំពេញបន្ថែមនូវភាពខ្វះចន្លោះនៅក្នុងឯកសារដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

ក្របខណ្ឌពេលវេលាដែលត្រូវបានបញ្ចូលនៅក្នុងផែនការអនុវត្តន៍ គ្រាន់តែជាសេចក្តីណែនាំប៉ុណ្ណោះ ហើយពេលវេលាទាំងនោះគួរត្រូវធ្វើការកែសម្រួលទៅតាមភាពរីកចំរើនរបស់គម្រោង ដោយយោងទៅតាមធនធានដែលអាចប្រើប្រាស់បានក្នុងគម្រោង និងសេចក្តីត្រូវការរបស់ប្រទេស កម្ពុជា។

## ៤-ក្របខណ្ឌច្បាប់អន្តរជាតិ

បច្ចុប្បន្ន ពុំមាននិយមន័យទេសចរណ៍ផ្លូវភេទលើកុមារដែលមានការឯកភាពជាអន្តរជាតិឡើយ[8]។ និយមន័យដែលអង្គការ ECPAT International បានបង្កើត និងមានការគាំទ្រពីអង្គការ UNODC បាន ពណ៌នាទេសចរណ៍ផ្លូវភេទលើកុមារថាជា ៖

> …ទេសចរណ៍ផ្លូវភេទលើកុមារ គឺជាការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារដោយជនម្នាក់ ឬច្រើននាក់ដែលធ្វើដំណើរពីស្រុកកំណើតរបស់ពួកគេ តំបន់ភូមិសាស្ត្រកំណើតរបស់ពួកគេ ឬប្រទេសកំណើតរបស់ពួកគេដើម្បីមានទំនាក់ទំនងផ្លូវភេទជាមួយកុមារ។ ទេសចរណ៍ផ្លូវភេទលើកុមារ អាចជាអ្នកធ្វើដំណើរក្នុងស្រុក ឬអាចជាទេសចរណ៍អន្តរជាតិ។ [ទេសចរណ៍ផ្លូវភេទលើកុមារ] តែងពាក់ព័ន្ធការ ប្រើប្រាស់កន្លែងស្នាក់នៅ មធ្យោបាយធ្វើដំណើរ និងសេវាកម្មទេសចរណ៍ដទៃទៀត ដែលសម្រប សម្រួលដល់ទំនាក់ទំនងជាមួយកុមារ និងបង្កលក្ខណៈឱ្យជនល្មើសនៅតែអាចបន្តធ្វើឱ្យប្រជាជន និងបរិយាកាសជុំវិញមិនចាប់អារម្មណ៍មកលើពួកគេ[9]។

---

[8] ChildWise, Travelling Child Sex Offenders in South East Asia: A Regional Review – 2007/2008, p3

[9] Ibid: referenced in ECPAT International, Combating Child Sex Tourism: Questions and Answers (2008) p6

ទេសចរណ៍ផ្លូវភេទលើកុមារ គឺជាប្រភេទឧក្រិដ្ឋកម្មមួយ ដែលឆ្លងកាត់ព្រំដែនច្បាប់ ជាមួយនឹងកាតព្វកិច្ចអន្តរជាតិ ដែលទាក់ទងទៅនឹងកិច្ចការពារកុមារពីទេសចរណ៍ផ្លូវភេទលើកុមារ ដែលប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ រំលោភបំពានទៅលើសិទ្ធិមនុស្ស និងច្បាប់ការងារ។ របាយការណ៍នេះនឹងប្រើប្រាស់និយមន័យទេសចរណ៍ផ្លូវភេទលើកុមាររបស់ ECPAT ជាមូលដ្ឋាន ដើម្បីយល់អំពីក្របខ័ណ្ឌច្បាប់អន្តរជាតិ និងវិភាគទៅលើការឆ្លើយតបនៅក្នុងប្រទេសកម្ពុជា។

កម្រងបទដ្ឋានច្បាប់អន្តរជាតិដ៏ទូលំទូលាយមួយ កំណត់ក្របខណ្ឌការងារសម្រាប់ការអភិវឌ្ឍ ឱ្យមាននូវការឆ្លើយតបពីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងប្រទេស ចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើ កុមារ។ លិខិតុបករណ៍អន្តរជាតិសំខាន់ៗ រួមមាន *អនុសញ្ញាស្តីពីសិទ្ធិកុមារ* (CRC) *(១៩៨៩) និងពិធីសារបន្ថែមនៃអនុសញ្ញានេះស្តីពីការជួញដូរកុមារ អំពើពេស្យាចារលើកុមារ និងរូបភាព អាសអាភាសនៃកុមារ (ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) (២០០០) អនុសញ្ញាសហ ប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនមានការរៀបចំទុក* (UNTOC) *(២០០០) និងពិធីសារនៃអនុសញ្ញា នេះដើម្បីទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ពិធីសារ ស្តីពីការជួញដូរមនុស្ស) (២០០៥) និងអនុសញ្ញា លេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សំរាប់ការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (អនុសញ្ញាលេខ ១៨២ របស់* ILO*) (១៩៩៩)*។ បើទោះបីជា លិខិតុបករណ៍មួយចំនួនដទៃទៀត ក៏រួមមានកាតព្វកិច្ចទូលំទូលាយ ដែលទាក់ទងទៅនឹង កិច្ចការពារកុមារក៏ដោយ[10] របាយការណ៍នេះនឹង ផ្តោតការយកចិត្តទុកដាក់ទៅលើក្របខ័ណ្ឌច្បាប់ទាំងនោះ ដែលមានរាយនាមខាងលើ ដែលភាគច្រើន មានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការឆ្លើយតបពីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះបញ្ហាទេសចរណ៍ ផ្លូវភេទលើកុមារ។

លិខិតុបករណ៍អន្តរជាតិមួយចំនួនដែលមិនចងកាតព្វកិច្ចគ្នា ក៏បានកំណត់ចំណុចដៅសំខាន់ៗមួយចំនួនសម្រាប់ការឆ្លើយតបក្នុងស្រុកចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារផងដែរ ឧទាហរណ៍ ដូចជា *សេចក្តីថ្លែងការណ៍ និងរបៀបវារៈសកម្មភាពទីក្រុងស្តុកហូម (១៩៩៦) និងការប្តេជ្ញាចិត្តសកល ទីក្រុងយូកូហាម៉ា (២០០១)* ប្រឆាំងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង*ក្រមសីលធម៌សកល (១៩៩៩)* នៃរដ្ឋជាសមាជិករបស់អង្គការទេសចរណ៍ពិភពលោកសហប្រជាជាតិ ដែលថ្កោលទោសចំពោះ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងអំពាវនាវឱ្យរដ្ឋនានា ធ្វើការផ្តន្ទាទោសទៅលើបទល្មើសទាំងនេះតាម រយៈបទប្បញ្ញត្តិជាតិ (រាប់បញ្ចូលបទប្បញ្ញត្តិដែលមានអំណាចក្រៅដែនដី)។ ឯកសារទាំងនេះ ពុំមាន ការ

[10] For example, International Covenant on Civil and Political Rights (ICCPR), Committee on the Elimination of Discrimination against Women (CEDAW), ILO Conventions 29, 105 and 138

ចងកាតព្វកិច្ចផ្លូវច្បាប់ឡើយ ប៉ុន្តែគោលការណ៍របស់វាបានឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចជាច្រើនដែល ត្រូវបានគូសបញ្ជាក់នៅក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិសំខាន់ៗ។

លិខិតុបករណ៍អន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ ត្រូវបានអនុម័តជ្រើសរើសយកទៅប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងតំបន់។ ប្រទេសកម្ពុជា គឺជារដ្ឋភាគីនៃលិខិតុបករណ៍អន្តរជាតិសំខាន់ៗទាំងនេះ។ តារាងខាងក្រោម បង្ហាញអំពីវិសាលភាព ដែលលិខិតុបករណ៍ទាំងនោះ ត្រូវបានផ្តល់សច្ចាប័ន (ឬទទួលបានការយល់ព្រម) នៅក្នុងប្រទេសអនុវត្តគម្រោងនិមួយៗ ៖

*តារាង ៖ ស្ថានភាពនៃការផ្តល់សច្ចាប័ន* [១១]

| *ប្រទេស* | *អនុសញ្ញាស្តីពីសិទ្ធិកុមារ* CRC | ពិធីសារបន្ថែមរបស់ CRC | អនុសញ្ញាសហប្រជាជាតិ UNTOC | ពិធីសារស្តីពីអំពើជួញដូរ មនុស្ស TIP Protocol | អនុសញ្ញា ILO លេខ ១៨២ |
|---|---|---|---|---|---|
| កម្ពុជា | ✓ | ✓ | ✓ | ✓ | ✓ |
| ឡាវ | ✓ | ✓ | ✓ | ✓ | ✓ |
| ថៃ | ✓ | ✓ | S | S | ✓ |
| វៀតណាម | ✓ | ✓ | ✓ | ✓ | ✓ |

[11] *UN Treaty Series <http://treaties.un.org> sourced at 28 August 2011; and http://www.ilo.org/ilolex/english/*

សេចក្តីពន្យល់:

✓: រដ្ឋភាគី [ប្រទេសដែលបានផ្តល់សច្ចាប័ន ឬយល់ព្រមលើលិខិតុបករណ៍]

s: ចុះហត្ថលេខា ប៉ុន្តែមិនផ្តល់សច្ចាប័ន

## ៥-១. អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម

អនុសញ្ញាស្តីពីសិទ្ធិកុមារ បានកំណត់ក្របខណ្ឌការងារទូលំទូលាយមួយស្តីពីសិទ្ធិមនុស្ស ដែលតម្រូវឱ្យរដ្ឋភាគីធ្វើសកម្មភាពដើម្បីឧត្តមប្រយោជន៍របស់កុមារ[១២]។ អនុសញ្ញាស្តីពីសិទ្ធិកុមារនេះគឺជាសន្ធិសញ្ញាមួយដែលត្រូវបានអនុម័តជ្រើសរើសយកទៅប្រើប្រាស់យ៉ាងទូលំទូលាយ ដោយរដ្ឋភាគីសរុបចំនួន ១៩៣[១៣]។ កម្ពុជាជារដ្ឋភាគីនៃអនុសញ្ញានេះ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ បានកំណត់បទដ្ឋានច្បាប់សំខាន់ៗមួយចំនួន ដែលទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ ជាពិសេស ដើម្បីការពារកុមារពីការរំលោភបំពាន ផ្លូវភេទ និងការផ្តល់យន្តការសមស្រប ដើម្បីអនុញ្ញាតឱ្យកុមារចូលរួមនៅក្នុងដំណើរការនីតិវិធីច្បាប់ ឬដំណើរការនីតិវិធីរដ្ឋបាល។ មាត្រា៣៤ និងមាត្រា៣៥ តម្រូវឱ្យរដ្ឋភាគីចាត់វិធានការសមស្របនៅក្នុងប្រទេស ដោយមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋដទៃទៀត ដើម្បីការពារកុមារពីរាល់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ រាប់បញ្ចូលការលួងលោម ឬការបង្ខិតបង្ខំឱ្យកុមារចូលរួមនៅក្នុងសកម្មភាពផ្លូវភេទខុសច្បាប់ណាមួយ[១៤] និងដើម្បីទប់ស្កាត់ការចាប់ខ្លួន ការលក់ ឬអំពើជួញដូរកុមារសម្រាប់គោលបំណងណាមួយ ឬនៅក្នុងទម្រង់ណាមួយ[១៥]។ ក្រោមមាត្រា១២ (២) រដ្ឋភាគីតម្រូវឱ្យផ្តល់ ឱកាសដល់កុមារ ដើម្បីឱ្យសម្លេងរបស់ពួកគេត្រូវបានគេឮនៅក្នុងដំណើរការនីតិវិធីតុលាការ ឬដំណើរការ នីតិវិធីរដ្ឋបាលដែលមានផលប៉ះពាល់ទៅលើកុមារដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬអង្គភាពសម ស្រប។ រដ្ឋអាចអនុវត្តលក្ខខណ្ឌតម្រូវនេះក្នុងលក្ខណៈមួយដែលមានសង្គតភាពទៅនឹងវិធាននីតិវិធីនៃ ច្បាប់ជាតិរបស់ពួកគេ[១៦]។

---

[12] Art 3

[13] UN Treaty Series <http://treaties.un.org> sourced at 28 August 2011

[14] Art 34

[15] Art 35

[16] Art 12(2)

ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បានកំណត់កាតព្វកិច្ចទៅលើរដ្ឋភាគីឱ្យចាត់វិធានការជាក់លាក់ ដើម្បីហាមឃាត់ចំពោះការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ [17] ដែលលិខិតុបករណ៍បានធ្វើការកត់សម្គាល់ថា សកម្មភាពទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ[18]។ និយមន័យដែលត្រូវបានកំណត់នៅក្នុងពិធីសារស្តីពី ការជួញដូរ កុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ មានភាពទូលំទូលាយដើម្បីក្តោបទៅលើ ការប្រព្រឹត្តជាច្រើនផ្សេងៗគ្នា៖

សម្រាប់គោលបំណងនៃពិធីសារបច្ចុប្បន្ន៖

(ក) ការជួញដូរកុមារ មានន័យថា រាល់សកម្មភាព ឬប្រតិបត្តិការទាំងឡាយណាដែលកុមារ ត្រូវបានផ្ទេរដោយជនណាម្នាក់ ឬមនុស្សមួយក្រុម ទៅឱ្យអ្នកដទៃដើម្បីទទួលបានប្រាក់កម្រៃ ឬការពិចារណាទទួលយកដទៃទៀត។

(ខ) ការធ្វើពេស្យាកម្មកុមារ មានន័យថា ការប្រើប្រាស់កុមារនៅក្នុងសកម្មភាពផ្លូវភេទ ដើម្បីទទួលបានប្រាក់កម្រៃ ឬការពិចារណាទទួលយកក្នុងទម្រង់ដទៃទៀត។

(គ) រូបភាពអាសអាភាសនៃកុមារ មានន័យថា ការតំណាងដោយមធ្យោបាយណាមួយ នៃកុមារ ដែលចូលរួមនៅក្នុងសកម្មភាពផ្លូវភេទដោយបើកចំហជាក់ស្តែង ឬក្លែងក្លាយ ឬការតំណាងណាមួយនៃអវយវៈភេទរបស់កុមារសម្រាប់គោលបំណងផ្លូវភេទជាចម្បង[19]។

ពិធីសារតម្រូវឱ្យរដ្ឋភាគីផ្តន្ទាទោសទៅលើសកម្មភាពទាំងនេះ មិនចំពោះថាបទល្មើសត្រូវបានប្រព្រឹត្តដោយរបៀបណាឡើយ (ឧទាហរណ៍ ការប្រព្រឹត្តគួររួមចំណែកបង្កើតឱ្យមាននូវបទល្មើសមួយ

[17] មាត្រា១ ខណៈពេលដែលអង្គការមួយចំនួនចូលចិត្តប្រើពាក្យ "សម្ភារៈរំលោភបំពានកុមារ" ឬ "រូបភាពរំលោភបំពានកុមារ" របាយការណ៍នេះនឹងប្រើប្រាស់ពាក្យ "រូបភាពអាសគ្រោមកុមារ" ដើម្បីឱ្យមានសង្គតភាពទៅនឹងវាក្យស័ព្ទបច្ចេកទេសច្បាប់ ដែលត្រូវបានប្រើប្រាស់នៅក្នុង លិខិតុបរណ៍ច្បាប់អន្តរជាតិពាក់ព័ន្ធ។

[18] បុព្វកថា ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

[19] Art 2

មិន ចំពោះថាបទល្មើសនោះត្រូវបានប្រព្រឹត្តដោយបុគ្គល ឬដោយមានការគ្រោងទុក ប្រព្រឹត្តនៅក្នុងប្រទេស ឬឆ្លងកាត់ប្រទេសឡើយ [២០] ។ បន្ថែមពីនេះទៀត ពិធីសារតម្រូវឱ្យធ្វើការផ្តន្ទាទោសទៅលើការប្រព្រឹត្តខាង ក្រោមដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ និងត្រូវផ្តន្ទាទោសទៅលើបទល្មើសនេះ ដោយការដាក់ទណ្ឌកម្មឱ្យបានធ្ងន់ធ្ងរ[២១]៖

- ការផ្តល់ ការប្រគល់ ឬការទទួលយកកុមារ ដោយមធ្យោបាយណាមួយសម្រាប់គោលបំណងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ការផ្គត់ផ្គង់ ការទទួលបាន ការធ្វើលទ្ធកម្ម ឬការផ្តល់កុមារសម្រាប់ពេស្យាកម្មកុមារ
- ការផលិត ការចែកចាយ ការផ្សព្វផ្សាយ ការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ ការលក់ ឬការមានជាកម្មសិទ្ធិនូវរូបភាពអាសអាភាសនៃកុមារ និង
- ការប៉ុនប៉ងប្រព្រឹត្តសកម្មភាពណាមួយខាងលើ និងការឃុបឃិត ឬការចូលរួមនៅក្នុងសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពទាំងនេះ[២២]។

ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ តម្រូវឱ្យរដ្ឋភាគីអនុវត្តយុត្តាធិការទៅលើបទល្មើសទាំងនេះ នៅពេលដែលបទល្មើសកើតឡើងនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋ (ឬនៅលើនាវា ឬយន្តហោះដែលបានចុះបញ្ជីជាមួយរដ្ឋនោះ)[២៣]។ បន្ថែមពីលើលក្ខខណ្ឌតម្រូវមូលដ្ឋាននេះ ដែលទាមទារឱ្យធ្វើ ការអះអាងអំពីយុត្តាធិការនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋ ពិធីសារបន្ថែមតម្រូវឱ្យរដ្ឋធ្វើការអះអាងអំពីយុត្តាធិការនៅក្នុងស្ថានភាពដែលរដ្ឋអាចបដិសេធ ឬធ្វើបត្យាប័នជនល្មើសដែលត្រូវចោទណាមួយក្រោមមូលដ្ឋាននៃជនជាតិដែលក្នុងករណីបែបនេះ តម្រូវឱ្យបញ្ជូនបញ្ហានេះទៅអាជ្ញាធរក្នុងប្រទេសរបស់ពួកគេដើម្បីធ្វើការផ្តន្ទាទោស[២៤]។ កាតព្វកិច្ចនេះ ស្ថិតក្រោមពិធីសារដែលឆ្លុះបញ្ចាំងអំពីគោលការណ៍ច្បាប់អន្តរជាតិ *aut dedere aut judicare*[25] ដែលតម្រូវឱ្យរដ្ឋធ្វើបត្យាប័ន ឬផ្តន្ទាទោសជនល្មើសដែលត្រូវចោទ និង

---

[20] Art 3

[21] Art 3(3)

[22] Art 3(1)-(2)

[23] Art 4(1)

[24] Art 4(3); Art 5(5)

[25] Latin for “extradite or prosecute”

ភាគច្រើនអនុវត្តចំពោះតែបទល្មើសកម្រិតធ្ងន់បំផុតប៉ុណ្ណោះ ដើម្បីធានាថា ពុំមានរដ្ឋណាមួយអាច ជាឋានសួគ៌ប្រកបដោយសុវត្ថិភាព សម្រាប់ជនដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់ឡើយ។

ពិធីសារក៏បានផ្តល់ឱកាសជូនដល់បណ្តារដ្ឋនានា ឱ្យធ្វើការពោលអះអាងកាន់តែទូលំទូលាយជាងមុន អំពីយុត្តាធិការចំពោះបទល្មើសដែលមិនកើតឡើងនៅក្នុងប្រទេសរបស់ពួកគេ[២៦]។ បើទោះបីជាវាពុំមែនជាកាតព្វកិច្ចដែលតម្រូវឱ្យអនុវត្តក៏ដោយ រដ្ឋភាគីអាចបង្កើតឱ្យមាននូវយុត្តាធិការទៅលើបទល្មើសនានាដែលត្រូវបានគូសបញ្ជាក់នៅក្នុងមាត្រា៣នៃពិធីសារ ប្រសិនបើជនល្មើសដែលត្រូវចោទគឺជាជនជាតិនៃរដ្ឋនោះ (ឬមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ) ឬជនរងគ្រោះគឺជាជនជាតិនៃរដ្ឋនោះ។ ជម្រើសនៃការបង្កើតអំណាចតុលាការក្រៅដែនដីនេះ ត្រូវបានអនុវត្តនៅក្នុងច្បាប់ជាតិនៃរដ្ឋមួយចំនួន ដែលជាភាគីនៃពិធីសារបន្ថែម ដើម្បីអនុញ្ញាតឱ្យមានការផ្តន្ទាទោសទៅលើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ ជាពិសេស ជនជាតិ ឬពលរដ្ឋដែលរស់នៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋដែលធ្វើការផ្តន្ទាទោសនោះ នៅពេលដែលពួកគេត្រឡប់ទៅកាន់ផ្ទះរបស់ពួកគេវិញ។

រដ្ឋភាគី តម្រូវឱ្យផ្តល់វិធានការជំនួយទូលំទូលាយមួយទៅឱ្យគ្នាទៅវិញទៅមក ដើម្បីសម្របសម្រួលដល់ដំណើរការស៊ើបអង្កេត ការផ្តន្ទាទោស និងការធ្វើបត្យាប័ន ដែលទាក់ទងទៅនឹងបទល្មើសផ្លូវភេទលើកុមារ[២៧] និងដើម្បីចាត់វិធានការរឹបអូសប្រាក់ចំណូលដែលទទួលបានពីបទល្មើសទាំងនោះ[២៨]។ ក្នុងនោះរាប់បញ្ចូលការធានាថា បទល្មើសដែលត្រូវបានគូសបញ្ជាក់នៅក្នុងមាត្រា៣ នៃពិធីសារបន្ថែម គឺជាបទល្មើសដែលអាចធ្វើបត្យាប័នបាន និងការធានាថា រដ្ឋអាចធ្វើបត្យាប័នបាន មិនចំពោះថារដ្ឋនោះមាន ឬគ្មានទំនាក់ទំនងសន្ធិសញ្ញាជាមួយរដ្ឋស្នើសុំឡើយ (លើកលែងករណីដែលរដ្ឋណាមួយមានបំណង អនុវត្តយុត្តាធិការទៅលើជនជាតិរបស់ខ្លួនក្នុងការផ្តន្ទាទោស ដូចមានគូសបញ្ជាក់ខាងលើ)[២៩]។ រដ្ឋភាគី ក៏មានកាតព្វកិច្ចធ្វើការងាររួមគ្នា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈការរៀបចំពហុភាគី ការរៀបចំកម្រិតតំបន់ និងការរៀបចំទ្វេភាគីសម្រាប់សកម្មភាពទប់ស្កាត់ ការស្វែងរក ការ

---

[26] Art 4(2)

[27] Art 6

[28] Art 7

[29] Art 5

ស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសទៅលើជនដែលទទួលខុសត្រូវចំពោះការជួញដូរកុមារ ការធ្វើពេស្យា- កម្មកុមារ រូបភាពអាសអាភាសកុមារ និងបទល្មើសទេសចរណ៍ផ្លូវភេទលើកុមារ[៣០]។

បន្ថែមពីលើកាតព្វកិច្ចដែលទាក់ទងទៅនឹងការផ្តន្ទាទោស បញ្ញាយុត្តាធិការ និងកិច្ចសហប្រតិ- បត្តិការអន្តរជាតិ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក៏បានកំណត់ឱ្យមាននូវក្របខ័ណ្ឌមួយសម្រាប់បណ្តារដ្ឋនានា ដើម្បីអនុម័តជ្រើសរើសយកវិធានការសមស្រប ដើម្បីការពារសិទ្ធិ និងប្រយោជន៍របស់កុមាររងគ្រោះ តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ[៣១] និងតម្រូវឱ្យធ្វើការគិតគូរពិចារណាបឋម ទៅលើឧត្តមប្រយោជន៍របស់កុមារ នៅពេលប្រព្រឹត្តចំពោះកុមាររងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[៣២]។ នៅក្នុងករណីដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ វិធានការពិសេសៗ មួយចំនួនដើម្បីឱ្យកុមាររងគ្រោះចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ គឺមានសារៈសំខាន់ខ្លាំងណាស់ អាស្រ័យដោយវិធានការទាំងនោះជួយដល់រដ្ឋ ក្នុងការធានាឱ្យមាននូវកិច្ចការពារចំពោះសិទ្ធិ និងប្រយោជន៍របស់កុមារ និងតាមរយៈការសម្របសម្រួលឱ្យមានការចូលរួមរបស់កុមារ នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌបែបនេះ វាក៏អាចជួយដល់ភ្នាក់ងារអនុវត្តន៍ច្បាប់ដើម្បីប្រើប្រាស់ភស្តុតាងរបស់ពួកគេសម្រាប់ចងក្រងអង្គហេតុស៊ើបអង្កេតកាន់តែរឹងមាំជាងមុន និងបង្កើនឱកាសក្នុងការផ្តន្ទាទោសប្រកបដោយភាពជោគជ័យ។ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ផ្តល់នូវបញ្ជីរាយនាមគ្រប់ជ្រុងជ្រោយមួយអំពីវិធានការដែល រដ្ឋត្រូវអនុម័តជ្រើសរើសមកប្រើប្រាស់ ក្នុងនោះរួមមានដូចជា ៖

- ការទទួលស្គាល់អំពីភាពងាយរងគ្រោះរបស់កុមាររងគ្រោះ និងការកែសម្រួលនីតិវិធីដើម្បីទទួលស្គាល់អំពីតំរូវការពិសេសរបស់កុមារ រាប់បញ្ចូលកុមារជាសាក្សី ផងដែរ
- ផ្តល់ព័ត៌មានជូនដល់កុមាររងគ្រោះអំពីសិទ្ធិរបស់ពួកគេ តួនាទីរបស់ពួកគេ ព្រមទាំងវិសាលភាព ពេលវេលា និងវឌ្ឍនភាពនៃដំណើរការនីតិវិធីបណ្តឹង និងការសម្រេចបញ្ចប់រឿងក្តីរបស់ពួកគេ
- អនុញ្ញាតឱ្យបង្ហាញ និងពិចារណាទៅលើទស្សនៈតំរូវការ និងបញ្ហាកង្វល់របស់កុមារ រងគ្រោះ នៅក្នុងដំណើរការនីតិវិធីបណ្តឹង ក្នុងករណីដែលប្រយោជន៍ផ្ទាល់ខ្លួនរបស់កុមារទទួលរងផលប៉ះពាល់

[30] Art 10(1)

[31] Art 8(1)

[32] Art 8(3)

- ផ្តល់សេវាគាំទ្រសមស្របជូនដល់កុមាររងគ្រោះ តាមរយៈដំណើរការច្បាប់
- ផ្តល់កិច្ចការពារទៅតាមភាពសមស្របចំពោះភាពឯកជន និងអត្តសញ្ញាណរបស់កុមាររងគ្រោះ ព្រមទាំងចាត់វិធានការ ដើម្បីជៀសវាងការផ្សព្វផ្សាយមិនសមស្របនូវព័ត៌មានមួយចំនួនដែលទាក់ទងទៅនឹងអត្តសញ្ញាណកុមារ
- ក្នុងករណីសមស្រប ត្រូវផ្តល់សុវត្ថិភាពជូនដល់កុមាររងគ្រោះ (ព្រមទាំងគ្រួសារ និងសាក្សីរបស់ពួកគេ) ដើម្បីឱ្យជៀសផុតពីការគំរាមកំហែង និងការតបត និង
- ជៀសវាងការពន្យាពេលដែលមិនចាំបាច់នៅក្នុងការសម្រេចបញ្ចប់រឿងក្តី និងការចេញដីកា ឬសាលក្រមដែលទាមទារសំណងចំពោះកុមាររងគ្រោះ[៣៣]។

គួរកត់សម្គាល់ថា ស្ថិតក្រោមអនុសញ្ញាស្តីពីសិទ្ធិកុមារ កុមារត្រូវបានកំណត់និយមន័យថា ជាជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ[៣៤]។ បើទោះបីជាលិខិតុបករណ៍អន្តរជាតិមួយចំនួនអនុញ្ញាតផ្តល់ឱ្យរដ្ឋនូវឆន្ទានុសិទ្ធិមួយចំនួន ក្នុងការកំណត់ទៅលើកម្រិតអាយុសមស្រប ដើម្បីទទួលបានចំនួនកុមារកាន់តែច្រើនក៏ដោយ លិខិតុបករណ៍សំខាន់ៗដែលទាក់ទងទៅនឹងកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ រាប់បញ្ចូលពិធីសារស្តីពីការជួញដូរមនុស្ស និងអនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិ បានកំណត់អាយុ១៨ឆ្នាំ ថាជាកម្រិតអាយុសម្រាប់កុមារ។ សម្រាប់គោលបំណងនៃរបាយការណ៍នេះ គេបានអនុម័តជ្រើសរើសការកំណត់និយមន័យរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារទៅលើពាក្យថា "កុមារ" យកមកប្រើប្រាស់។

## ៤-២. ពិធីសារស្តីពីអំពើជួញដូរមនុស្ស

ពិធីសារស្តីពីការជួញដូរមនុស្ស ដែលបំពេញបន្ថែមទៅលើ UNTOC តម្រូវឱ្យរដ្ឋចាត់វិធានការ ដើម្បីទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសទៅលើករណីជួញដូរមនុស្ស។ កម្ពុជា គឺជារដ្ឋភាគីនៃ UNTOC និងពិធីសារស្តីពីអំពើជួញដូរមនុស្ស។

[33] Art 8(1)

[34] Article 1

ខណៈពេលដែលទេសចរណ៍ផ្លូវភេទលើកុមារ គឺជាទម្រង់មួយដោយឡែកនៃសកម្មភាពឧក្រិដ្ឋ ដែលទាមទារឱ្យមាននូវការអនុវត្តន៍វិធានការក្នុងប្រទេសដែលកំណត់គោលដៅជាក់លាក់ បញ្ហានេះក៏មានទំនាក់ទំនងជិតស្និទ្ធទៅនឹងការជួញដូរកុមារផងដែរ [៣៥] ។ ស្ថិតក្រោមពិធីសារស្តីពីអំពើជួញដូរមនុស្ស កុមារ ត្រូវបានកំណត់និយមន័យថា ជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ [៣៦] ។ សម្រាប់និយមន័យនៃអំពើជួញដូរមនុស្ស ពិធីសារស្តីពីអំពើជួញដូរមនុស្សតម្រូវឱ្យមានធាតុផ្សំចំនួន៣ ៖

- <u>សកម្មភាព</u> ៖ ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងស្នាក់នៅ ឬការទទួលយកមនុស្ស
- <u>មធ្យោបាយ</u> ៖ តាមរយៈការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ឬទម្រង់ដទៃទៀតនៃ ការបង្ខិតបង្ខំ ការចាប់ខ្លួន ការបោកបន្លំ ការបំភ័ន្ត ការរំលោភអំណាច ឬស្ថានភាពនៃ ភាពងាយរងគ្រោះ ឬការផ្តល់ ឬការទទួលប្រាក់កម្រៃ ឬប្រយោជន៍ ដើម្បីទទួលបានការយល់ព្រមពីជនដែលមានឥទ្ធិពលគ្រប់គ្រងទៅលើជនដទៃទៀត
- <u>គោលបំណង</u> ៖ សម្រាប់គោលបំណងកេងប្រវ័ញ្ច។ ត្រឹមកម្រិតអប្បបរមា ការកេងប្រវ័ញ្ចត្រូវរាប់បញ្ចូល ការកេងប្រវ័ញ្ចទៅលើពេស្យាកម្មរបស់អ្នកដទៃ ឬទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការបង្ខំឱ្យធ្វើពលកម្ម ឬផ្តល់សេវាកម្មទាសភាព ឬការអនុវត្តដែលស្រដៀងគ្នាទៅនឹងទាសភាព សេវភាព ឬការដកហូតសរីរាង្គ[៣៧]។

បើទោះជាដូច្នេះក្តី ក្នុងករណីដែលកុមារត្រូវបានជ្រើសរើស ផ្ទេរ ដឹកជញ្ជូន ផ្តល់កន្លែងស្នាក់នៅ ឬត្រូវបានគេទទួលយកសម្រាប់គោលបំណងកេងប្រវ័ញ្ច ចំណុចនេះនៅតែរួមចំណែកចំពោះករណីជួញដូរមនុស្សដដែល បើទោះបីជាពុំមានការប្រើប្រាស់មធ្យោបាយខាងលើក៏ដោយ[៣៨]។ អាចនិយាយបានថា ដើម្បីប្រព្រឹត្តបទល្មើសជួញដូរកុមារ ត្រូវទាមទារឱ្យមានធាតុផ្សំពីរគឺ “សកម្មភាព” និង “មធ្យោបាយ”។ នេះគឺដោយសារតែកុមារ មិនអាចផ្តល់ការយល់ព្រម ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យគេកេងប្រវ័ញ្ចបានឡើយ ដូច្នេះក្នុងករណីនេះ គេមិនចាំបាច់ត្រូវបង្ហាញអំពីការបោកបញ្ឆោត ឬការបង្ខិតបង្ខំនោះទេ។ សកម្មភាព ដែលមានបំណងសម្របសម្រួលដល់ទេសចរណ៍ផ្លូវភេទលើកុមារ ក៏អាចរួមចំណែក

---

[35] ECPAT, Mind the Gaps, p12

[36] Art 3(d)

[37] Art 3(a)

[38] Art 3(c)

ចំពោះករណីជួញដូរ មនុស្សផងដែរ។ ឧទាហរណ៍ បុគ្គលម្នាក់ដែលស្វែងរក ឬអូសទាញកុមារណាម្នាក់ សម្រាប់គោលបំណង បណ្តាលឱ្យ ឬអនុញ្ញាតឱ្យកុមារម្នាក់នោះត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ មិនចំពោះថាការកេងប្រវ័ញ្ចនោះត្រូវបានធ្វើឡើងដោយ ឬមិនត្រូវបានធ្វើឡើងដោយជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ ឡើយ បុគ្គលម្នាក់នេះបានប្រព្រឹត្តបទល្មើសជួញដូរមនុស្ស បើយោងតាមនិយមន័យដែលកំណត់នៅក្នុងពិធីសារ។ ម្យ៉ាងវិញទៀត ប្រសិនបើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារធ្វើការរំលោភបំពាន ឬ កេងប្រវ័ញ្ចទៅលើកុមារដែលត្រូវបានជួញដូរ ពួកគេនឹងត្រូវទទួលខុសត្រូវ ដោយយោងទៅតាមច្បាប់ដទៃទៀតដែលគ្របដណ្តប់ទៅលើការរំលោភបំពានរាងកាយ និងផ្លូវភេទលើកុមារ។

ដូច្នេះ គេចាំបាច់ត្រូវកំណត់រកកាតព្វកិច្ចសំខាន់ៗដែលស្ថិតនៅក្រោមពិធីសារស្តីពីការជួញដូរមនុស្ស អាស្រ័យដោយកាតព្វកិច្ចទាំងនោះមានទំនាក់ទំនងទៅនឹងការផ្តន្ទាទោសទៅលើសកម្មភាពដែល ពាក់ព័ន្ធទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ នៅក្នុងបទប្បញ្ញត្តិជាតិ ការអនុវត្តវិធានការសម្រាប់ការពារ កុមារ តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងការអភិវឌ្ឍយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែន។ កាតព្វកិច្ចសំខាន់ៗដែលស្ថិតនៅក្រោមពិធីសារស្តីពី ការជួញដូរមនុស្ស ក៏មានសង្គតភាពយ៉ាងជិតស្និទ្ធទៅនឹងកាតព្វកិច្ច ដែលស្ថិតនៅក្រោមពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីសិទ្ធិកុមារផងដែរ។

រដ្ឋតម្រូវឱ្យផ្តន្ទាទោសទៅលើការប្រព្រឹត្តដែលត្រូវបានគូសបញ្ជាក់ខាងលើ រាប់បញ្ចូលការបង្កើតឱ្យមាននូវការទទួលខុសត្រូវមូលដ្ឋានទៅលើឧក្រិដ្ឋកម្ម និងបទល្មើសនានា ដែលទាក់ទងទៅនឹងការប៉ុនប៉ងការចូលរួមក្នុងនាមជាអ្នកសមគំនិត និងការរៀបចំ ឬការបញ្ជាអ្នកដទៃឱ្យប្រព្រឹត្តបទល្មើ[៣៩]។ កាតព្វកិច្ចដទៃទៀតរបស់រដ្ឋភាគីចំពោះពិធីសារស្តីពីការជួញដូរមនុស្ស ឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសំខាន់ៗមួយចំនួនដែលរួមមាននៅក្នុងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សម្រាប់កិច្ចការពារកុមាររងគ្រោះ និងសាក្សី។ ជាពិសេសរដ្ឋតម្រូវឱ្យអនុវត្តវិធានការដែល ៖

- ការពារភាពឯកជន និងអត្តសញ្ញាណរបស់ជនរងគ្រោះ រាប់បញ្ចូលការរៀបចំដំណើរការ នីតិវិធីច្បាប់ ដែលទាក់ទងទៅនឹងការរក្សាការសម្ងាត់នៃអំពើជួញដូរ[៤០]

[39] Art 4

[40] Art 6(1)

- ផ្តល់ព័ត៌មានជូនដល់ជនរងគ្រោះអំពីតុលាការ និងដំណើរការនីតិវិធីរដ្ឋបាលពាក់ព័ន្ធ និងផ្តល់ជំនួយ ដើម្បីបង្កលក្ខណៈឱ្យទស្សនៈ និងបញ្ហាកង្វល់របស់ពួកគេត្រូវបានលើកយកមកបង្ហាញនៅក្នុងដំណើរការនីតិវិធីករណីព្រហ្មទណ្ឌ[៤១]
- ធានាថា តំរូវការពិសេសរបស់កុមារ ត្រូវបានយកមកពិចារណានៅក្នុងដំណើរការ ច្បាប់[៤២]
- ខិតខំធានាសុវត្ថិភាពផ្លូវកាយរបស់ជនរងគ្រោះ[៤៣]។

ស្ថិតក្រោមអនុសញ្ញានៃពិធីសារស្តីពីការជួញដូរមនុស្សរបស់ UNTOC រដ្ឋភាគីតម្រូវឱ្យផ្តល់កិច្ចសហប្រតិបត្តិការតាមរយៈការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិសាលភាពមួយ ដែលមានលក្ខណៈទូលំទូលាយបំផុត ដូចដែលអាចធ្វើទៅបាន[៤៤]។ UNTOC បានកំណត់កាតព្វកិច្ចដែល ស្រដៀងគ្នាទៅនឹងកាតព្វកិច្ចនៅក្នុងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សម្រាប់ការបង្កើតយុត្តា- ធិការទៅលើបទល្មើសនានា [៤៥] ដូច្នេះវាក៏រួមមានកាតព្វកិច្ចស្រដៀងគ្នាដែលទាក់ទងទៅនឹងការកំណត់ថា ករណីជួញដូរមនុស្ស គឺជាបទល្មើសមួយដែលអាចធ្វើបត្យាប័នបាន និងការតម្រូវឱ្យគោរពតាមគោល-ការណ៍ *aut dedere aut judicare*[៤៦]។ អង្គការ UNTOC និងពិធីសារស្តីពីការជួញដូរមនុស្ស ក៏បានអំពាវនាវឱ្យរដ្ឋភាគីផ្តល់កិច្ចសហប្រតិបត្តិការនៅកម្រិតភ្នាក់ងារ ដើម្បីចែករំលែកព័ត៌មានអំពីការអនុវត្តច្បាប់[៤៧]។

---

[41] Art 6(2)

[42] Art 6(4)

[43] Art 6(5)

[44] Arts 16; 18(1)-(2)

[45] Art 15

[46] Arts 15-16

[47] មាត្រា ១០ (១) នៃពិធីសារស្តីពីការជួញដូរមនុស្ស ព្រមទាំងមានឆ្លុះបញ្ចាំងផងដែរនៅក្នុងមាត្រា ២៧ នៃ UNTOC

# ៤-៣. អនុសញ្ញាអង្គការពលកម្មកុមារអន្តរជាតិលេខ១៨២៖ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

អនុសញ្ញាលេខ១៨២ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមាររបស់អង្គការ ILO ទទួលស្គាល់អំពីភាពងាយរងគ្រោះជាពិសេសរបស់កុមារ និងបានដាក់កម្រិតទៅលើធម្មជាតិនៃការងារដែលពួកគេអាចចូលរួមធ្វើ ក្នុងករណីដែលការងារនោះត្រូវបានគេយល់ឃើញថា មានគ្រោះថ្នាក់បំផុតចំពោះកុមារ។ អនុសញ្ញាតម្រូវឱ្យរដ្ឋចាត់វិធានការ ដើម្បីធានាដល់ការហាមប្រាម និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ[48]។ ប្រទេសកម្ពុជា គឺជារដ្ឋភាគីនៃ អនុសញ្ញាលេខ១៨២ របស់អង្គការ ILO។

ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រាប់បញ្ចូលការប្រើប្រាស់ ការធ្វើលទ្ធកម្ម ឬការផ្តល់ឱ្យកុមារបម្រើក្នុងពេស្យាកម្ម ការផលិតរូបភាពអាសអាភាស ឬការសំដែងអាសអាភាស[49] ព្រមទាំងការលក់ និងការជួញដូរកុមារ[50]។ វិធានការដើម្បីហាមប្រាម និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អាចរាប់បញ្ចូលការកំណត់ទោសព្រហ្មទណ្ឌ ឬទោសទណ្ឌដទៃទៀតទៅតាមភាពសមស្រប[51]។ អនុសញ្ញាលេខ១៨២ របស់អង្គការ ILO មិនបានរៀបរាប់លម្អិតអំពីវិធានការបន្ថែមទៀត ដើម្បីធ្វើការហាមប្រាម និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឡើយ។ បើទោះជាដូច្នេះក្តី អនុសញ្ញានេះបានធ្វើការឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយអំពីកាតព្វកិច្ចជាក់លាក់ជាច្រើន ដែលស្ថិតនៅក្រោមពិធីសារបន្ថែមរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ រាប់បញ្ចូលការតម្រូវឱ្យរដ្ឋភាគីធ្វើការផ្តន្ទាទោសទៅលើការប្រព្រឹត្តមួយចំនួនដែលទាក់ទងទៅនឹងការជួញដូរកុមារ អំពើពេស្យាចារលើកុមារ និងរូបភាពអាសអាភាសនៃកុមារ[52]។

---

[48] Art 1

[49] Art 3(a)

[50] Art 3(a)

[51] Art 7(1)

[52] ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១ និងមាត្រា៣

# ៥-ក្របខ័ណ្ឌច្បាប់ប្រទេសកម្ពុជា

## ៥-១. ស្ថានភាពនៃការផ្តល់សច្ចាប័នទៅលើលិខិតុបករណ៍អន្តរជាតិសំខាន់ៗ

កម្ពុជាបានផ្តល់សច្ចាប័នទៅលើលិខិតុបករណ៍នីមួយៗ ក្នុងចំណោមលិខិតុបករណ៍អន្តរជាតិទាំង៥ ដែលមានចងកាតព្វកិច្ចសំខាន់ៗសម្រាប់រដ្ឋ ដើម្បីធ្វើការអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ។ ជាពិសេស ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាស្តីពីសិទ្ធកុមារ (ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២) និងលើពិធីសារជ្រើសរើសស្តីពីការជួញដូរកុមារ អំពើពេស្យាចារលើកុមារ និងរូបភាពអាសអាភាសនៃកុមារ (ថ្ងៃទិ៣០ ខែឧសភា ឆ្នាំ២០០២)។

## ៥-២. ការផ្តន្ទាទោស និងទោសប្បញ្ញត្តិសម្រាប់ការប្រព្រឹត្តទេសចរណ៍ផ្លូវភេទ លើកុមារ

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួមមានកម្រងនៃកិច្ចការពារមួយចំនួន ដើម្បីប្រឆាំងទៅនឹងការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ខណៈពេលដែលច្បាប់មិនបានសំដៅជាក់លាក់ចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ បទល្មើសដែលគ្របដណ្តប់ទៅលើទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរកុមារ ដែលមានលក្ខណៈទូលំទូលាយជាងនេះ អាចពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសទៅលើការប្រព្រឹត្តដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។

យោងតាមបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងការកេងប្រវ័ញ្ចផ្លូវភេទ ក៏ត្រូវបានកំណត់នៅក្នុងមាត្រា៤៦ និងមាត្រា៤៨ នៃ*រដ្ឋធម្មនុញ្ញនៃព្រះរាជា-ណាចក្រកម្ពុជា (១៩៩៣)* ផងដែរ[៥៣]។ មាត្រា៤៦ នៃរដ្ឋធម្មនុញ្ញចែងថា "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះ ពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់"។ មាត្រា៤៨ចែងថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋ

[53] Art 48

គាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ“ ។ យោងតាមសេចក្តីសម្រេចនៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះក្នុងឆ្នាំ២០០៧ បានចែងថាតុលាការត្រូវតែពឹងផ្អែកទៅលើ ច្បាប់ដោយរាប់បញ្ចូលទាំងច្បាប់រដ្ឋធម្មនុញ្ញ (ដែលជាច្បាប់កំពូលប្រចាំប្រទេស) ក៏ដូចជាអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយប្រទេសកម្ពុជា ជាពិសេសអនុសញ្ញាស្តីពីសិទ្ធកុមារ។ សេចក្តីសម្រេចនេះបញ្ជាក់ថាតុលាការនៃប្រទេសកម្ពុជា ជាអ្នកអនុវត្តអនុសញ្ញាស្តីពីសិទ្ធកុមារ និងពិធីសារជ្រើសរើសស្តីពីការជួញដូរកុមារ អំពើពេស្យាចារលើកុមារ និងរូបភាពអាសអាភាសនៃកុមារនៅក្នុងស្រុក។

ការកំណត់នៅក្នុងច្បាប់បែបនេះ បានបង្កើតឱ្យមាននូវវេទិការឹងមាំមួយសម្រាប់តួនាទីរបស់រដ្ឋនៅ ក្នុងកិច្ចការពារកុមារពីរាល់គ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ រាប់បញ្ចូលទាំងទេសចរណ៍ផ្លូវភេទផងដែរ។

*ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ* (២០០៨) (ច្បាប់ TIPSE) បានផ្តល់នូវកម្រងបទល្មើសគ្រប់ជ្រុងជ្រោយ ដែលទាក់ទងទៅនឹងពេស្យាកម្មកុមារ ការរំលោភបំពានផ្លូវភេទ រូបភាពអាសអាភាសកុមារ និងការជួញដូរកុមារសម្រាប់គោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានគោលបំណងអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ក្រោមពិធីសារស្តីពីការជួញដូរមនុស្ស និងលិខិតុបករណ៍អន្តរជាតិដទៃទៀត ដែលទាក់ទងទៅនឹង ការជួញដូរមនុស្ស[៥៤]។ បើទោះជាដូច្នេះក្តី ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ មានវិសាលភាព និងការអនុវត្តទូលំទូលាយ ព្រមទាំងកំណត់ការផ្តន្ទាទោសព្រហ្មទណ្ឌ ដែលការកំណត់បែបនេះ ក៏បានឆ្លុះបញ្ចាំងអំពីកាតព្វកិច្ច ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារផងដែរ។ ស្ថិតក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការទទួលខុសត្រូវ ចំពោះបទល្មើសព្រហ្មទណ្ឌ ត្រូវបានកំណត់និយមន័យទូលំទូលាយ ដើម្បីបញ្ចូលការប៉ុនប៉ងប្រព្រឹត្ត បទល្មើស និងការធ្វើសកម្មភាពក្នុងនាមជាជនសមគំនិត និងផ្តើមគំនិត (រាប់បញ្ចូលការរៀបចំ និង ការបញ្ជាអ្នកដទៃឱ្យប្រព្រឹត្តបទល្មើស) ហើយការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌពង្រីកការ គ្របដណ្តប់ទៅលើអង្គភាពនីតិបុគ្គលទាំងមូល បន្ថែមពីលើរូបវន្តបុគ្គល[៥៥]។

---

[54] Art 1

[55] Art 4

ស្របតាមបទដ្ឋានអន្តរជាតិ អនីតិជន ត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទថា ជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ[៥៦]។ មាត្រា៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សន្មតថា ជនណាដែលរក្សាទុកអនីតិជនឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ឬត្រួតពិនិត្យរបស់ខ្លួននឹងត្រូវចាត់ទុកថាបានដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះបង្ហាញឱ្យឃើញថា ខ្លួនមានការជឿជាក់ ដោយសមហេតុផលថា អនីតិជននោះមានអាយុ១៨ឆ្នាំ ឬច្រើនជាង១៨ឆ្នាំ។

បទល្មើសដែលមានការទាក់ទងជាក់លាក់ទៅនឹងការជួញដូរកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ត្រូវផ្តន្ទាទោសធ្ងន់ធ្ងរជាងក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងបទល្មើសដែលប្រព្រឹត្តទៅលើមនុស្សពេញវ័យ ដែលចំណុចនេះឆ្លុះបញ្ចាំងអំពីស្ថានទម្ងន់ទោសនៃបទល្មើស នៅពេលប្រព្រឹត្តទៅលើកុមារ។

### *៥.២.១-ពេស្យាចារលើកុមារ*

ជំពូក៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានរៀបរាប់ទាក់ទងទៅនឹងបញ្ហាពេស្យាចារលើកុមារ។ ពេស្យាកម្មកុមារត្រូវបានកំណត់និយមន័យថាជា "ការរួមភេទ ឬគ្រប់ទម្រង់នៃការប្រព្រឹត្តផ្លូវភេទដទៃទៀតរវាងអនីតិជន និងបុគ្គលដទៃ ដើម្បីប្តូរនឹងវត្ថុអ្វីមួយដែលមានតម្លៃ"[៥៧]។ និយមន័យដ៏ទូលំទូលាយនៃពាក្យថាពេស្យាចារលើកុមារនេះ អាចគ្របដណ្តប់ទៅលើសកម្ម ភាពដែលមានទំនាក់ទំនងជាក់លាក់ជាមួយបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ ដែលជាញឹកញាប់តែងពាក់ព័ន្ធ ទៅនឹងជនល្មើសម្នាក់ដែលរួមភេទ ឬប្រព្រឹត្តសកម្មភាពផ្លូវភេទដទៃទៀតជាមួយកុមារ ដើម្បីប្តូរនឹងវត្ថុអ្វីមួយមានតម្លៃ។ អ្វីដែលសំខាន់នោះគឺ សម្រាប់បញ្ហាពេស្យាចារលើកុមារ ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ធាតុផ្សំនៃបទល្មើសដែលទាក់ទងទៅនឹង "ការប្តូរនឹងអ្វីមួយដែលមានតម្លៃ" រាប់បញ្ចូលការផ្តល់ ឬការសន្យាផ្តល់អ្វីមួយដែលមាន តម្លៃទៅ

---

[56] Art 7

[57] Art 23

ឱ្យកុមារ ឬអន្តរការី ឪពុក ឬម្តាយ អាណាព្យាបាល ឬជនដទៃទៀតដែលគ្រប់គ្រងទៅលើកុមារ[58]។ ការបែងចែកនេះមានសារៈសំខាន់ណាស់ អាស្រ័យដោយវាធានាថា ការផ្តន្ទាទោសទៅលើករណីពេស្យាចារលើកុមារ មានវិសាលភាពទូលំទូលាយ និងរាប់បញ្ចូលស្ថានភាពដែលជនល្មើសផ្តល់ប្រាក់ (ឬអ្វីម្យ៉ាងដែលមានតម្លៃ) ទៅឱ្យជនដែលរៀបចំពេស្យាកម្ម ជំនួសឱ្យការផ្តល់ប្រាក់ដោយផ្ទាល់ទៅឱ្យកុមារ។ ស្ថិតក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទោសប្បញ្ញត្តិសម្រាប់ករណីពេស្យាកម្មកុមារ គឺជនល្មើសនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ២-៥ឆ្នាំ ក្នុងករណីកុមារមានអាយុ ១៥ឆ្នាំឡើងទៅ និង ផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ៧-១៥ឆ្នាំ ក្នុង ករណីកុមារមានអាយុក្រោម ១៥ឆ្នាំ។

ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បទល្មើសដទៃទៀតដែលទាក់ទងទៅនឹងពេស្យាចារកុមាររួមមាន៖ ការធ្វើលទ្ធកម្មពេស្យាចារកុមារ (រាប់បញ្ចូលការទទួលបានប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចារ និងការជ្រើសរើស ឬការលួងលោមឱ្យជនណាម្នាក់ចូលទៅបម្រើអំពើពេស្យាចារ)[59] ការគ្រប់គ្រងពេស្យាចារកុមារ ការគ្រប់គ្រងគ្រឹះស្ថានពេស្យាចារកុមារ និងការផ្តល់ទីកន្លែងសម្រាប់ពេស្យាចារកុមារដែលករណីនីមួយៗ នឹងត្រូវផ្តន្ទាទោសដោយការដាក់ពន្ធនាគារពី ៧-១៥ឆ្នាំ[60] ការធ្វើលទ្ធកម្មនៃអំពើពេស្យាកម្មដោយការធ្វើទារុណកម្ម នឹងត្រូវផ្តន្ទាទោសពី ១០-២០ឆ្នាំ[61] ការអូសទាញពេស្យាចារកុមារ (រាប់បញ្ចូលការអូសទាញ ឬការផ្សព្វផ្សាយពាណិជ្ជកម្ម ក្នុងនាមជាអន្តរការី) នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី២-៥ឆ្នាំ និងពិន័យជាប្រាក់ចន្លោះពីបួនលានទៅដប់លានរៀល និងផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី៥-១០ឆ្នាំ ក្នុងករណីដែលបទល្មើស ត្រូវបានប្រព្រឹត្តដោយជនណាម្នាក់ដែលកំពុងធ្វើប្រតិបត្តិការក្នុងលក្ខណៈជាអាជីវកម្ម[62]។ រីតែតែសំខាន់ជាងនេះ គឺច្បាប់អាចឱ្យកុមាររួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើពួកគេត្រូវបានរកឃើញថា ពួកគេត្រូវបានគេលួងលោមក្នុងគោលបំណងធ្វើពេស្យាចារលើពួកគេ។ ការផ្តល់ប្រាក់កម្ចី ឬរបស់មានតម្លៃដទៃទៀត និងការចុះកិច្ចសន្យា សម្រាប់គោលបំណងពេស្យាចារកុមារ ក៏ត្រូវបានចាត់ទុកថាជា បទល្មើសព្រហ្មទណ្ឌផងដែរ[63]។

---

[58] Art 34

[59] Arts 25; 28

[60] Arts 30 – 33

[61] Art 29

[62] Art 35

[63] Arts 36 & 37

*ក្រមព្រហ្មទណ្ឌ*នៃព្រះរាជាណាចក្រកម្ពុជា (២០០៧) ហាមឃាត់ទៅលើការធ្វើលទ្ធកម្មពេស្យាកម្ម កុមារ រាប់បញ្ចូលៈ ការទទួលបានប្រយោជន៍ហិរញ្ញវត្ថុពីពេស្យាចាររបស់អ្នកដទៃ ការផ្តល់ជំនួយ ឬការពារពេស្យាកម្មរបស់អ្នកដទៃ ឬការគ្រប់គ្រងដំណើរការសកម្មភាពពេស្យាចារ ការជ្រើសរើស ការចាប់ខ្លួន ឬការអូសទាញជនណាម្នាក់ឱ្យក្លាយជាជនពេស្យា និងការដាក់សម្ពាធទៅលើជនណាម្នាក់ឱ្យក្លាយជាជនពេស្យា[64]។ ក្នុងករណីជនដែលចូលនៅក្នុងសកម្មភាពពេស្យាចារគឺជាអនីតិជន បទល្មើសលទ្ធកម្ម នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ៧-១៥ឆ្នាំ[65]។ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសត្រូវទទួលទោសដូចគ្នាទៅនឹងការប្រព្រឹត្តបទល្មើសដែរ[66]។ ទោះជាយ៉ាងណាក៏ដោយ និយមន័យនៃពាក្យថាអនីតិជន ពុំមានភាពច្បាស់លាស់ឡើយនៅក្នុងក្រមព្រហ្មទណ្ឌ។ បើទោះបីជាអនីតិជនត្រូវបានចាត់ទុកថាជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ សម្រាប់គោលបំណងកំណត់ទៅលើការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌក៏ដោយ[67] វាពុំមានភាពច្បាស់លាស់ថា តើនិយមន័យនេះគ្របដណ្តប់ទៅលើកុមារដែលជាជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌឡើយ។ អ្វីដែលសំខាន់នោះ គឺអង្គភាពនីតិបុគ្គលមានការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌ និងអាចកំណត់ទោសប្បញ្ញត្តិមួយចំនួន រាប់បញ្ចូលការពិន័យជាប្រាក់ (ចន្លោះពីដប់លានទៅហាសិបលានរៀល) និងទណ្ឌកម្មដទៃទៀតដូចជា ការបិទអាជីវកម្ម ការរឹបអូសទ្រព្យសម្បត្តិ និងការផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេច ដែលទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌរបស់អង្គភាព[68]។

### *៤.២.២-ការរំលោភបំពានផ្លូវភេទទៅលើកុមារ*

បន្ថែមពីលើបទល្មើសដែលទាក់ទងទៅនឹងពេស្យាកម្មកុមារ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហាមឃាត់ចំពោះការប្រព្រឹត្តផ្លូវភេទ ឬការរួមភេទជាមួយកុមារអាយុក្រោម១៥ឆ្នាំ។ ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ៥-១០ឆ្នាំ ហើយសកម្មភាពមិនសមរម្យទៅលើអនីតិជនអាយុក្រោម១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

---

[64] Art 284

[65] Art 289

[66] Art 294

[67] Art 38

[68] Art 296

ចន្លោះពី ១-៣ឆ្នាំ និងពិន័យជាប្រាក់ពី ពីរលាន ទៅ ប្រាំមួយលានរៀល[69]។ ត្រូវផ្តន្ទាទោសទ្វេដងនៃរយៈពេលដាក់ពន្ធនាគារ ចំពោះការប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសទាំងពីរនេះម្តងហើយម្តងទៀត[70]។ បទល្មើសទំនាក់ទំនងផ្លូវភេទជាមួយអនីតិជនក្រោមអាយុ ១៥ឆ្នាំ ត្រូវបានយកចិត្តទុកដាក់នៅក្នុងប្រទេសកម្ពុជា លើករណីនានាដែលជនល្មើសផ្លូវភេទលើកុមារបានធ្វើការរំលោភបំពានផ្លូវភេទទៅលើកុមារក្រោមអាយុ ១៥ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលកម្ពុជា ក៏បានរាយការណ៍ ពីការប្រឈមស្តីពីការប្រើប្រាស់មាត្រានេះ។ នៅក្នុងករណីខ្លះ ក្មេងប្រុស ដែលមានអាយុចន្លោះពី ១៥-១៨ឆ្នាំ ត្រូវបានគេផ្តន្ទាទោស និងដាក់ពន្ធធនាគារពីបទមានទំនាក់ទំនងផ្លូវភេទជាមួយក្មេងស្រីនៅក្នុងកាលៈទេសៈមួយដែលគ្មានបំណងប្រព្រឹត្តល្មើស។ ការអនុវត្តនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ គឺបញ្ហាដែលមិនអាចដាច់ស្រេច និងមិនអនុញ្ញាត្តិឱ្យមានវិសាលភាពនៃដំណោះស្រាយផ្សេងទៀតដែលជនល្មើសមានអាយុក្រោម១៨ឆ្នាំ។

បទប្បញ្ញត្តិទាំងនេះ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានសង្គតភាពទៅនឹងក្រមព្រហ្មទណ្ឌ ដែលកំណត់អំពីអាយុស្របច្បាប់ក្នុងការរួមភេទ ដែលបុគ្គលត្រូវមានអាយុ១៥ឆ្នាំ[71]។ បន្ថែមពីនេះទៀត ស្ថិតក្រោមក្រមព្រហ្មទណ្ឌ ការរំលោភសេពសន្ថវៈត្រូវបានហាមឃាត់ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ៥-១០ឆ្នាំ។ ទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទ (ដែលច្បាប់សំដៅហៅថា "អំពើប្រទូស្តកេរខ្មាស") ក៏ត្រូវបានហាមឃាត់ផងដែរ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ១-៣ឆ្នាំ និងពិន័យជាប្រាក់ចន្លោះពី ពីរលាន ទៅ ប្រាំមួយលានរៀល។ បទល្មើសទាំងពីរប្រភេទនេះ (ករណីរំលោភសេពសន្ថវៈ និង ទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទ) តម្រូវឱ្យការប្រព្រឹត្តត្រូវរួមមានអំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬការបង្កភាពភ្ញាក់ផ្អើល។ បទល្មើសទាំងនេះ ក៏មានការកំណត់ទោសប្បញ្ញត្តិធ្ងន់ធ្ងរជាងផងដែរ ក្នុងករណីដែលមានស្ថានទម្ងន់ទោស ឧទាហរណ៍ ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ឬការប្រព្រឹត្តបទល្មើសទៅលើជនដែលមានភាពងាយរងគ្រោះ ជាពិសេសដោយសារអាយុរបស់ពួកគេ។ ប្រភេទស្ថានទម្ងន់ទោសទាំងនេះ

[69] Art 42

[70] Art 43

[71] Art 239

អាចត្រូវបានយកមកអនុវត្ត ក្នុងករណី ការរំលោភបំពានផ្លូវភេទលើកុមារ ដោយជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ[៧២]។

### ៥.២.៣-រូបភាពអាសអាភាសនៃកុមារ

ការផ្តន្ទាទោសទៅលើរូបភាពអាសអាភាសកុមារ គឺជាធាតុផ្សំមួយដ៏សំខាន់ក្នុងការ ប្រយុទ្ធប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ ជាញឹកញាប់ ជនល្មើសទេសចរណ៍ផ្លូវភេទលើ កុមារ តែងចាប់ផ្តើមការស្រាវជ្រាវរកឱកាសកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ សកម្មភាពនេះ អាចរួមមានការជជែកលេងជាមួយជនល្មើសសក្តានុពលដទៃទៀតតាមប្រព័ន្ធអ៊ីនធឺណែត ដើម្បីចែករំលែកព័ត៌មាន និងសម្ភាររូបភាពអាសអាភាស។

ក្រោមច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រូបភាពអាសអាភាសនៃកុមារ អាចរាប់បញ្ចូលសម្ភារទស្សនីយភាពមួយចំនួនដូចជា រូបថត ឬវីដេអូ និងសម្ភារក្នុងទម្រង់អេឡិចត្រូនិច[៧៣]។ ក្រោមច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវចាត់ទុកថាជាបទល្មើស ចំពោះការរៀបចំឱ្យមាននូវរូបភាពអាសអាភាសកុមារ (តាមរយៈការចែកចាយ ការលក់ ការជួល ការដាក់តាំង ការចាក់បញ្ចាំង ឬ ការបង្ហាញនៅក្នុងកន្លែងសាធារណៈ) និងការមានជាកម្មសិទ្ធិ ការដឹកជញ្ជូន ការនាំចូល ឬនាំចេញ រូបភាពអាសអាភាសកុមារ សម្រាប់គោលបំណងរៀបចំឱ្យមាននូវសម្ភារទាំងនោះ ដែលបទល្មើសទាំង ពីរនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ២-៥ ឆ្នាំ និងពិន័យជាប្រាក់ចន្លោះពី បួនលាន ទៅ ដប់លានរៀល។ ការផលិតរូបភាពអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ៥-១០ឆ្នាំ ឬ ក្នុងករណីដែលសម្ភារទាំងនោះត្រូវបានផលិតសម្រាប់គោលបំណងរៀបចំឱ្យមាននូវសម្ភារទាំងអស់នោះ ដូចបានគូសបញ្ជាក់ខាងលើ ជនល្មើសនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ១០-២០ឆ្នាំ[៧៤]។

បើទោះបីជា ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានកំណត់

---

[72] Title 3, Chapters 1 & 2: Arts 239–252

[73] Art 39

[74] Art 41

ចែងអំពីការហាមឃាត់យ៉ាងទូលំទូលាយទៅលើការប្រើប្រាស់រូបភាពអាសអាភាស នៃកុមារសម្រាប់គោលបំណងចែកចាយក៏ដោយ ប៉ុន្តែច្បាប់នេះពុំបានកំណត់ចែងអំពីបទល្មើសមូលដ្ឋានមួយ នៃការមានជាកម្មសិទ្ធិនូវរូបភាពអាសអាភាសនៃកុមារ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឡើយ។ នេះគឺជាភាពខ្វះចន្លោះមួយគួរឱ្យកត់សម្គាល់ នៅក្នុងច្បាប់បច្ចុប្បន្ន។ ដូចគ្នានេះដែរ មាត្រា៣៩ *នៃ*ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនដោះស្រាយបញ្ហាចែកចាយ លក់ ជួល ដាក់តាំងបញ្ចាំង ឬបង្ហាញនូវរូបភាព និងសម្ភារអាសអាភាសនោះ នៅកន្លែងឯកជនឡើយ ដោយកន្លែងឯកជននេះសំដៅទៅលើកន្លែងសាធារណៈតែប៉ុណ្ណោះ។ ភាពខ្វះខាតនៃច្បាប់ព្រហ្មទណ្ឌប្រឆាំងនឹងការប្រើប្រាស់រូបភាពអាសអាភាសលើកុមារជាលក្ខណៈផ្ទាល់ខ្លួន គឺជាចន្លោះខ្វះខាតមួយដ៏សំខាន់នៅក្នុងច្បាប់។ ក្រសួងយុត្តិធម៌បានចង្អុលបង្ហាញថា ការបញ្ជាក់ឱ្យច្បាស់នូវពាក្យថា "ទីកន្លែងសាធារណៈ" និង "ទីកន្លែងឯកជន" អាចជួយដល់សមត្ថកិច្ចអនុវត្តច្បាប់ក្នុងការកំណត់អត្តសញ្ញាណបទល្មើសឱ្យបានសមស្រប។

### *៤.២.៤-ការជួញដូរកុមារ*

បទល្មើសជាច្រើន ដែលមានទំនាក់ទំនងជាក់លាក់ទៅនឹងការជួញដូរកុមារ ក៏ត្រូវបានកំណត់ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទផងដែរ។ ក្នុងនោះរាប់បញ្ចូលបទល្មើសដែលស្ថិតនៅក្រោមប្រភេទទូលំទូលាយនៃការលក់ ការទិញ ឬការផ្លាស់ប្តូរកុមារ និងការឃុំខ្លួនកុមារទុកដោយខុសច្បាប់[៧៥] សម្រាប់គោលបំណងកេងប្រវ័ញ្ច (ត្រូវបានកំណត់និយមន័យដើម្បីបញ្ចូលពេស្យាកម្ម រូបភាពអាសអាភាស សកម្មភាពអាជីវកម្មផ្លូវភេទ និងពលកម្មកុមារ)[៧៦]។ ដូចគ្នាទៅនឹងធាតុផ្សំដទៃទៀតនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបានគូសបញ្ជាក់ខាងលើផងដែរ ជំពូកដែលទាក់ទងទៅនឹងការជួញដូរមនុស្ស បានកំណត់ទោសប្បញ្ញត្តិធ្ងន់ធ្ងរជាងក្នុងករណីដែលបទល្មើសទាំងនោះ ត្រូវបានប្រព្រឹត្តចំពោះកុមារ។ បទល្មើសជួញដូរដែលស្ថិតនៅក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បើទោះបីជាមានទំនាក់ទំនងគ្នាក៏ដោយ ក៏បទល្មើសទាំងនោះ មានភាពខុសប្លែកពីការប្រព្រឹត្តដែលពាក់ព័ន្ធជាក់លាក់ទៅនឹងបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ ដែលបញ្ហានេះត្រូវបានគ្របដណ្តប់ប្រសើរជាង ដោយបទល្មើសពេស្យា កម្មកុមារ និងរូបភាពអាសអាភាសនៃកុមារ ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើ អាជីវកម្មផ្លូវភេទដែលបានរៀបរាប់ជូនដូចខាងលើ។ ជាពិសេស បទល្មើសជួញដូរជាច្រើន

---

[75] Chapters 2 & 3

[76] Art 10

ដែលស្ថិតក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តម្រូវឱ្យមានទំនាក់ទំនងរវាងការប្រព្រឹត្តបែបកេងប្រវ័ញ្ច (ឧទាហរណ៍ ការកេងប្រវ័ញ្ចផ្លូវភេទក្នុងទម្រង់ជាពេស្យាកម្ម) ជាមួយនឹងការផ្ទេរ ឬការដកហូតកុមារ រាប់បញ្ចូលការផ្ទេរកុមារឆ្លងកាត់ព្រំដែន។ អាស្រ័យដោយបទល្មើសជួញដូរ ស្ថិតក្រោមច្បាប់ស្តីពីការ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនសូវមានភាពពាក់ព័ន្ធទៅនឹងការប្រព្រឹត្ត ដែលជាទូទៅមានទំនាក់ទំនងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ ដូច្នេះបទល្មើសទាំងនេះ មិនត្រូវបាន យកមកពិចារណាលម្អិតនៅក្នុងរបាយការណ៍នេះឡើយ។

### *៥.២.៥-អន្តរកម្មរវាងច្បាប់*

ទាំងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានកំណត់អំពីបទល្មើសដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុងបរិបទទេសចរណ៍ផ្លូវភេទលើកុមារ និងមានភាពត្រួតស៊ីគ្នា នៅក្នុងវិស័យមួយចំនួន (ជាពិសេសនៅក្នុងបទល្មើសដោយឡែកពីគ្នានៃច្បាប់ទាំងនោះ ដែលទាក់ទងទៅនឹងពេស្យាចារកុមារ)។ មាត្រា៥០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា នៅក្នុងករណីដែលពុំមានការឯកភាពគ្នារវាងច្បាប់នានា គេត្រូវយកបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជាគោល។ បើទោះជាដូច្នេះក្តី វាមានភាពពាក់ព័ន្ធក្នុងការស្វែងរកដំបូន្មានពីមន្ត្រីកម្ពុជា ដើម្បីទទួលបានរូបភាពច្បាស់លាស់មួយអំពីលក្ខណៈនៃអន្តរទំនាក់ទំនង រវាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ និងដើម្បីបញ្ជាក់ថា តើបទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានបកស្រាយនៅក្នុងការអនុវត្តជាក់ស្តែងថា បានជំនួសទៅលើបទល្មើស ដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌដែរឬទេ។

### *៥.២.៦-ច្បាប់រដ្ឋបាល*

*ច្បាប់រដ្ឋបាល ក៏មានការពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា។ ច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍ (ប្រកាសដោយព្រះរាជក្រឹតលេខៈ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦) ប្រគល់អំណាចដល់ក្រសួងទេសចរណ៍ក្នុងការគ្រប់គ្រង*

*និងពិនិត្យទៅលើវិស័យទេសចរណ៍។ តែទោះជាយ៉ាងណាក៏ដោយ អាណត្តិរបស់វាទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ គឺមានកំណត់។*

បន្ថែមពីលើទណ្ឌកម្មព្រហ្មទណ្ឌ ដែលត្រូវបានគូសបញ្ជាក់ខាងលើ *ច្បាប់ស្តីពីទេសចរណ៍* ចែងថា អ្នកទេសចរ ឬអ្នកដំណើរដែលចូលរួមនៅក្នុងសកម្មភាពពាក់ព័ន្ធទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការ បោះពុម្ពរូបភាព និងសម្ភារអាសអាភាស នឹងត្រូវដកហូតទិដ្ឋាការទេសចរណ៍របស់ពួកគេ ព្រមទាំង ត្រូវនិរទេស ឬហាមឃាត់មិនឱ្យមកធ្វើទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលជាក់ លាក់ណាមួយ (មិនលើសពី៥ឆ្នាំ) ឬជាអចិន្ត្រៃយ៍។ បើទោះបីជាទណ្ឌកម្មរដ្ឋបាលទាំងនេះ បានធ្វើការ ហាមឃាត់ទៅលើទេសចរណ៍ផ្លូវភេទលើកុមារក៏ដោយ តែវាពុំមានភាពច្បាស់លាស់អំពីរបៀបដែលលក្ខខណ្ឌតម្រូវក្រោមច្បាប់ស្តីពីទេសចរណ៍ ក្នុងការដកហូតទិដ្ឋាការទេសចរណ៍ (និងនិរទេសភ្ញៀវទេសចរណ៍ចេញពីព្រះរាជាណាចក្រកម្ពុជា) អាចធ្វើប្រតិបត្តិការរួមគ្នាជាមួយការរៀបចំបណ្តឹងព្រហ្មទណ្ឌចំពោះការប្រព្រឹត្តតែមួយ។

ច្បាប់ស្តីពីទេសចរណ៍ ហាមអនីតិជនមិនឱ្យចូលទៅកាន់ទីបរិវេណ មណ្ឌល កម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ និងតម្រូវឱ្យអ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាប័ណ្ណនៃមណ្ឌលកម្សាន្តទាំងនោះត្រូវធានាថា មិនមានវត្តមានកុមារនៅទីនោះ។ *តែទោះជាយ៉ាងណាក៏ដោយ* ពុំមានការបំភ្លឺ និងការចាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ និងទំហំនៃទស្សនៈរបស់ច្បាប់នេះ ដែលត្រូវបានអនុវត្តគឺមិនទាន់បានដឹងច្បាស់នៅឡើយទេ។

អនុក្រឹតស្តីពីការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ របស់ក្រសួងមហាផ្ទៃ បញ្ជាក់ពីភារកិច្ចរបស់នាយកដ្ឋាននគរបាលទេសចរណ៍ ដើម្បីសហការជាមួយស្ថាប័នមានសមត្ថកិច្ចក្នុងការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋដូចជា ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងឃុំឃាំងមនុស្ស ការជួញដូរកុមារការកេងប្រវ័ញ្ចផ្លូវភេទ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ ដែលស្ថិតនៅក្រោមការដឹកនាំរបស់អគ្គស្នងការនគរបាលជាតិកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ភារកិច្ចរបស់នគរបាលទេសចរណ៍ មានភាពជាន់គ្នាជាមួយនឹងនាយកដ្ឋាប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ហើយអាជ្ញាធរមានសមត្ថកិច្ចរបស់ពួកគេ ត្រូវបានកំណត់ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តាស្ថាប័នផ្សេងៗទៀត។

## ៥.៣ វិធានការស្តីពីកិច្ចការពារកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

ពុំមានវិធានការជាក់លាក់ណាមួយសម្រាប់កិច្ចការពារកុមារ នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌក្រោមច្បាប់កម្ពុជាឡើយ។ បើទោះជាដូច្នេះក្តី ឯកសារគោលនយោបាយបានចែងអំពីគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារអនុវត្តន៍ច្បាប់ និងភ្នាក់ងារយុត្តិធម៌ ដើម្បីធានាថា វិធានការការពារកុមារតាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបានយកមកអនុវត្ត។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) គឺជាយន្តការសម្របសម្រួលមួយនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ដែលមានអាណត្តិការងារលើកកម្ពស់ការរស់រានមានជីវិត ការអភិវឌ្ឍ និងកិច្ចការពារកុមារ ព្រមទាំងលើកកម្ពស់សុខុមាលភាព និងការចូលរួមរបស់កុមារ[77]។ គោលដៅយុទ្ធសាស្ត្រមួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រនានារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គឺជា "ច្បាប់ និងគោលនយោបាយសម្រាប់កុមារ" ដែលរាប់បញ្ចូលធាតុចេញ និងការវិភាគទៅលើច្បាប់ និងគោលនយោបាយ បច្ចុប្បន្ន ការតស៊ូមតិ និងការផ្តល់ជំនួយ ដើម្បីបំពេញភាពខ្វះចន្លោះដែលត្រូវបានកំណត់រកឃើញ និងការធ្វើសមាហរណកម្មច្បាប់ និងគោលនយោបាយថ្មីៗ នៅក្នុងស្ថាប័នរដ្ឋាភិបាល និងស្ថាប័ន មិនមែនរដ្ឋាភិបាល[78]។ ឯកសារគោលនយោបាយ ដែលបានរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានផ្តល់នូវចំណុចដៅសំខាន់ៗមួយចំនួន សម្រាប់ការពារកុមារដែលជាជន រងគ្រោះ និងសាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ឧទាហរណ៍ *គោលការណ៍ណែនាំសម្រាប់កិច្ច ការពារសិទ្ធិកុមារ ដែលត្រូវបានជួញដូរនៃព្រះរាជាណាចក្រកម្ពុជា* (២០០៧) បានផ្តល់សេចក្តីណែនាំមួយចំនួន ដើម្បីធានាថា សិទ្ធិរបស់កុមារត្រូវបានការពារពីគ្រប់បណ្តាភ្នាក់ងារពាក់ព័ន្ធទាំងអស់ រាប់បញ្ចូល ការធានាឱ្យមានការគិតគូរពិចារណាខ្ពស់បំផុតទៅលើឧត្តមប្រយោជន៍របស់កុមារ និងអនុសាសន៍សម្រាប់ ធ្វើកិច្ចសម្ភាសន៍ដែលផ្តោតការយកចិត្តទុកដាក់ទៅលើកុមារ សន្តិសុខ និងកិច្ចការពារកុមាររងគ្រោះ និងសាក្សី ព្រមទាំងការរៀបចំអនុវត្តដំណើរការនីតិវិធីព្រហ្មទណ្ឌ។ គោលការណ៍ណែនាំនេះ បង្ហាញ អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តវិធានការការពារសម្រាប់កុមាររងគ្រោះ និងសាក្សីដែល ជាជនងាយរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ បើទោះជាដូច្នេះក្តី គោលការណ៍ណែនាំ និង របាយការណ៍របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សុទ្ធសឹងតែបានភ្ជាប់ទំនាក់ទំនងរវាងការកេងប្រវ័ញ្ច ផ្លូវភេទទៅនឹងការជួញដូរកុមារ ឬដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទ ក្នុងលក្ខណៈមួយដែលកាន់តែ ទូលំទូលាយ។ **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មិនទាន់បោះពុម្ពឧបករណ៍លិខិតុបករណ៍គោល នយោបាយណាមួយ ដែលមានលក្ខ**

---

[77] ផែនការយុទ្ធសាស្ត្ររបស់ CNCC ទំព័រទី១៣

[78] p17–18

ណៈជាក់លាក់ទៅនឹងបញ្ហាកិច្ចការពារកុមាររងគ្រោះ និងសាក្សី នៅក្នុងករណីទេសចរណ៍ផ្លូវភេទ ឡើយ។

ក្រសួងយុត្តិធម៌មិនបានធ្វើសេចក្តីណែនាំស្តីពីការចោទប្រកាន់ ការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលផ្តោតលើការអនុវត្តគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិដែលនៅជាធរមាន ទាក់ទងទៅនឹងកិច្ចការពារជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ និងសេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងទៅនឹងនីតិវិធីយុត្តិធម៌អនីតិជន។ ក្រសួងក៏បានចេញប្រកាស[79] ស្តីពីការប្រើបាំងក្នុងបន្ទប់សវនាការ និងបន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ (ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៨)។ បន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ ត្រូវបានបំពាក់នៅក្នុងសាលាដំបូងរាជធានីខេត្តចំនួន ៥។ ក៏ប៉ុន្តែនីតិវិធី និងឧបករណ៍កុមារមេត្រីទាំងនេះ ស្ទើរតែមិនបានប្រើប្រាស់។

ឯកសារណែនាំគោលនយោបាយដទៃទៀត ក៏បានកំណត់ចែងអំពីមូលដ្ឋានទូលំទូលាយមួយសម្រាប់កិច្ចការពារកុមាររងគ្រោះ និងសាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌផងដែរ។ ឧទាហរណ៍ *កម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* (២០០៨-២០១៣) ចែងថា ក្រោមអាទិភាពរបស់ខ្លួន សំដៅពង្រឹង និងពង្រីកសេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា ក្រសួងលើកកម្ពស់កិច្ចការពារសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ និងប្រព័ន្ធតុលាការ ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ [៨០] ។ ក្របខណ្ឌច្បាប់ដែលមានលក្ខណៈទូលំទូលាយជាងនេះ ក៏បានកំណត់ចែងអំពីកិច្ចការពារ មួយចំនួនដែលមានកម្រិតផងដែរ។ ក្រោម*ច្បាប់ស្តីពីរបបសារព័ត៌មាន* សារព័ត៌មានត្រូវបានហាមឃាត់មិនឱ្យបោះពុម្ពផ្សាយព័ត៌មានរូបភាព ឬរូបគំនូរ ដែលអាចសម្រេបសម្រួលដល់ការកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់អាយុក្រោម១៨ឆ្នាំ ដែលចូលរួមនៅក្នុងករណីបណ្តឹងរដ្ឋប្បវេណី ឬព្រហ្មទណ្ឌឡើយ លុះត្រាណាតែតុលាការផ្តល់ការអនុញ្ញាតឱ្យធ្វើយ៉ាងដូច្នេះ [៨១]។ ក្រោម*ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ* ជនរងគ្រោះមានសិទ្ធិទទួលបានភាពជាតំណាងតាមផ្លូវច្បាប់នៅ គ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីបណ្តឹង។ បើទោះជាដូច្នេះក្តី ពុំមានច្បាប់ ឬគោលនយោបាយណាតែមួយ ដែលអាច

---

[79] Proclamations (Prakas): A proclamation is a ministerial or inter-ministerial decision signed by the relevant Minister(s). A proclamation must conform to the Constitution and to the law or sub-decree to which it refers.

[80] p6

[81] Art 15

ដោះស្រាយបាននូវវិធានការស្តីពីកិច្ចការពារ ដែលពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ តម្រូវឱ្យអនុវត្តសម្រាប់ កុមាររងគ្រោះ និងសាក្សីឡើយ ហើយក៏ពុំមានក្របខណ្ឌដែលមានស្រាប់ណាមួយដែលអាចដោះស្រាយ បញ្ហានេះនៅក្នុងបរិបទជាក់លាក់នៃបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារនោះដែរ។

## ៥.៩-វិធានការសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែន

ក្របខណ្ឌច្បាប់ របស់កម្ពុជាសម្រាប់ការធ្វើបត្យាប័ន ត្រូវបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[៨២]។ ក្រមនេះបាន កំណត់ចែងអំពីកម្រងលក្ខខណ្ឌតម្រូវគ្រប់ជ្រុងជ្រោយមួយសម្រាប់អនុវត្តដំណើរការនីតិវិធីធ្វើបត្យាប័ន បើទោះជាដូច្នេះក្តី វាពុំមានភាពច្បាស់លាស់ថា តើការធ្វើបត្យាប័នអាចត្រូវបានអនុញ្ញាតសម្រាប់រាល់ករណី បទល្មើសទាំងអស់ ឬសម្រាប់តែករណីបទល្មើសជាក់លាក់មួយចំនួនប៉ុណ្ណោះ។

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាការពារអំណាចតុលាការក្រៅដែនដី ទៅលើបទល្មើសទាំងឡាយណា ដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលផ្តន្ទាទោសយ៉ាងទូលំទូលាយទៅលើបទល្មើសដែលមានទំនាក់ទំនងដោយផ្ទាល់ ទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ អនុវត្តអំណាចតុលាការក្រៅដែនដី។ មាត្រា២ និងមាត្រា៣ អនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងក្រៅដែនសមត្ថកិច្ចនៃប្រទេសនេះ ហើយគេអនុវត្តយុត្តាធិការក្រៅដែនសមត្ថកិច្ចនៃប្រទេស ចំពោះករណីដែលជនល្មើសដែលត្រូវចោទ ឬជនរងគ្រោះគឺជាពលរដ្ឋកម្ពុជា[៨៣]។ ក្រមព្រហ្មទណ្ឌក៏បានកំណត់ចែងអំពីការអនុវត្តអំណាចតុលាការក្រៅដែនដីដែលមានលក្ខណៈស្រដៀងគ្នា ចំពោះករណីបទល្មើសរំលោភបំពានផ្លូវភេទផងដែរ[៨៤]។

---

[82] គន្ថី៩ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៥៦៦ ដល់មាត្រា៥៩៥។

[83] Arts 2 & 3

[84] Arts 20 & 21

## ៥.៥. សង្ខេប និងអនុសាសន៍

ក្របខណ្ឌច្បាប់ និងគោលនយោបាយបច្ចុប្បន្ន បង្ហាញអំពីការប្តេជ្ញាចិត្តដ៏រឹងមាំរបស់កម្ពុជាក្នុងការការពារកុមារពីរាល់គ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ។ បើទោះជាដូច្នេះក្តី មានការងារជាច្រើនទៀតដែលគេអាចអនុវត្ត ដើម្បីដោះស្រាយបញ្ហាការប្រព្រឹត្តដែលមានទំនាក់ទំនងជាក់លាក់ទៅនឹងទេសចរណ៍ ផ្លូវភេទលើកុមារ។ សរសរស្តម្ភនៃយុទ្ធសាស្ត្រស្តីពីយុត្តិធម៌ព្រហ្មទណ្ឌរបស់សេចក្តីព្រាង *ផែនការសកម្មភាព ជាតិស្តីពីការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ* (២០១១-២០១៣) (NPA) បញ្ជាក់អំពីសកម្មភាពដែលត្រូវអនុវត្ត ដើម្បីពង្រឹងក្របខណ្ឌច្បាប់ រាប់បញ្ចូលការរៀបចំសេចក្តីព្រាងច្បាប់ ដើម្បីបំពេញភាពខ្វះចន្លោះនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបច្ចុប្បន្ន។ បើទោះបីជាសេចក្តីថ្លែងគោលនយោបាយនេះ ផ្តោតការយកចិត្តទុកដាក់ទៅលើការជួញដូរមនុស្សក៏ដោយ ដោយយោងទៅតាមទំនាក់ទំនងរវាងការ ជួញដូរសម្រាប់ គោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងទេសចរណ៍ផ្លូវភេទលើកុមារ ព្រមទាំងចង្កោមនៃបទល្មើសទូលំទូលាយ ដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលត្រូវបានគ្របដណ្តប់ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ សេចក្តីព្រាងផែនការសកម្មភាពជាតិ ក៏អាចត្រូវបានគេមើលឃើញថាជាសូចនាករមួយនៃចេតនារបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាភាពខ្វះចន្លោះច្បាប់ ដែលទាក់ទងទៅនឹង ទេសចរណ៍ផ្លូវភេទលើកុមារឱ្យបានទូលំទូលាយ ជាងនេះ។

ច្បាប់ និងគោលនយោបាយដែលមានស្រាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់នូវវេទិកាមួយដ៏រឹងមាំសម្រាប់ការអភិវឌ្ឍកំណែទម្រង់ច្បាប់បន្ថែមទៀត ដើម្បីផ្តន្ទាទោសទៅលើរាល់ទម្រង់នៃការប្រព្រឹត្ត ដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ បើទោះបីជាច្បាប់ជាក់លាក់មួយដែលផ្តោតទិសដៅទៅលើបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ អាចបញ្ជូនសារដ៏មុឹងម៉ាត់មួយទៅឱ្យជនល្មើសសក្តានុពលថា សកម្មភាពឧក្រិដ្ឋបែបនេះ នឹងមិនត្រូវបានអត់ឱននៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ ចំណុចខ្លាំងនៃយន្តការច្បាប់ដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ មានន័យថា គេពុំចាំបាច់ត្រូវបង្កើតបទប្បញ្ញត្តិថ្មីដោយឡែកឡើយ។

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈស្របទៅនឹងកាតព្វកិច្ចអន្តរជាតិសំខាន់ៗជាច្រើន ដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមាររួចទៅហើយ ប៉ុន្តែបើទោះជាដូច្នេះក្តី គេអាចពង្រឹងទៅលើ

វិស័យជាក់លាក់មួយចំនួនបន្ថែមទៀត ដើម្បីផ្តល់នូវក្របខណ្ឌការងារមួយ ដែលកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងមុន សម្រាប់ប្រឆាំងទៅនឹងអំពើទេសចរណ៍ផ្លូវភេទលើកុមារ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (និងបន្ទាប់មក គឺក្រមព្រហ្មទណ្ឌ) ផ្តន្ទាទោសទៅលើចង្កោមនៃការប្រព្រឹត្តទូលំទូលាយមួយចំនួន ដែលទាក់ទងទៅនឹងការលក់កុមារ អំពើពេស្យាចារលើកុមារ និងរូបភាពអាសអាភាសនៃកុមារ ព្រមទាំងមានវិសាលភាពទូលំទូលាយ រាប់បញ្ចូលបទល្មើសប៉ុនប៉ង និងចូលរួមក្នុងនាមជាអ្នកសមគំនិត ឬអ្នកផ្តើមគំនិត ការពង្រីកការ ទទួលខុសត្រូវចំពោះករណីព្រហ្មទណ្ឌជូនដល់អង្គភាពនីតិបុគ្គល ការកំណត់ទោសប្បញ្ញត្តិធ្ងន់ធ្ងរដែលឆ្លុះបញ្ចាំងអំពីភាពធ្ងន់ធ្ងរនៃបទល្មើស និងស្វែងរកការបង្ការទប់ស្កាត់បទល្មើសមិនរាងចាល។

បើទោះជាដូច្នេះក្តី គេឃើញមានភាពខ្វះចន្លោះមួយដ៏សំខាន់នៅក្នុង បទល្មើសព្រហ្មទណ្ឌបច្ចុប្បន្ន។ ច្បាប់ពុំមានផ្តន្ទាទោសទៅលើបទល្មើសមូលដ្ឋាន នៃការមានជាកម្មសិទ្ធិ នូវរូបភាពអាសអាភាសនៃកុមារ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន (និង ពុំមែនសម្រាប់គោលបំណងចែកចាយ)។ បន្ថែមពីនេះទៀតការរំលោភបំពានផ្លូវភេទទៅលើកុមារអាយុក្រោម១៥ឆ្នាំ ក៏ត្រូវបានផ្តន្ទាទោសផងដែរ (ស្ថិតក្រោមក្រមព្រហ្មទណ្ឌ)។ បើទោះជាដូច្នេះក្តី វាពុំមានភាពច្បាស់លាស់ ថាតើមានបទល្មើសស្រដៀងគ្នាសម្រាប់ផ្តន្ទាទោសទៅលើការរំលោភបំពានផ្លូវភេទលើកុមារអាយុចន្លោះពី ១៥-១៨ឆ្នាំ ដែលខុសប្លែកគ្នាពីការប្រព្រឹត្តបទល្មើសទៅលើមនុស្សពេញវ័យឡើយ។ អន្តរកម្មរវាងបទប្បញ្ញត្តិដែលមានលក្ខណៈស្រដៀងគ្នានៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏ពុំមានភាពច្បាស់លាស់ផងដែរ។

ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានពង្រឹងបន្ថែម ដោយដាក់បញ្ចូលនូវការផ្តន្ទាទោសឱ្យជាលាក់មួយទៅលើការប្រព្រឹត្តល្បួង។ ការល្បួង កើតមានឡើងនៅពេលដែលជនល្មើសផ្លូវភេទកុមារ ទាំងអ្នកធ្វើដំណើរ និងមិនធ្វើដំណើរដែលស្វែងរកការផ្តួចផ្តើម និងកសាងទំនាក់ទំនងជាមួយកុមារ ដោយប្រើប្រាស់ទំនាក់ទំនងនោះដើម្បីកសាងទំនុកចិត្តសម្រាប់គោលដៅក្នុងការសម្រួលដល់ការកេងប្រវ័ញ្ចផ្លូវលើកុមារទាំងនោះ។ យោងតាមការបកស្រាយរបស់ Europol លើពាក្យថា ល្បួងគឺជាធាតុផ្សំនៃបទល្មើស ដែលរួមមានការរៀបចំគម្រោងដោយចេតនា ដើម្បីជួបជាមួយកុមារ (ដែលមិនទាន់គ្រប់អាយុដែលច្បាប់បានកំណត់ សម្រាប់សកម្មភាពកេងប្រវ័ញ្ចផ្លូវភេទ) ដើម្បីធ្វើការ រំលោភបំពានផ្លូវភេទ។ សហរដ្ឋអាមេរិក ចាត់ទុកថា ការប្រព្រឹត្តល្បួង គឺជាសកម្មភាពមួយនៃការបង្កើត ឱ្យមានទំនាក់ទំនងផ្លូវអារម្មណ៍ដោយចេតនា ជាមួយកុមារណាម្នាក់ ដើម្បីរៀបចំធ្វើការរំលោភបំពានលើកុមារម្នាក់នោះ។ ប្រភេទនៃការល្បួង កើតមានឡើងតាមរយៈសេវាទំនាក់ទំនង ដូចជាប្រព័ន្ធអ៊ីនធើណេត ឬទូរស័ព្ទចល័តដែលជនល្មើសប្រើប្រាស់ដើម្បីទាក់ទងជាមួយកុមារ។ ក្នុងករណីជាច្រើនជនល្មើស ជាដំបូងចាប់ផ្តើម

ណែនាំខ្លួនរបស់ពួកគេថាជាកុមារម្នាក់ ឬជាក្មេង ដោយធ្វើការណែនាំកុមារដែលជា គោលដៅសម្រាប់ធ្វើការរំលោភបំពានឱ្យស្គាល់ពីភាពសប្បាយរីករាយផ្លូវភេទ ឬរូបភាពអាសអាភាស និងក្នុងករណីខ្លះទៀត ពួកគេលួងលោមកុមារឱ្យឈានចូលដល់ការផលិតរូបភាពអាសអាភាសនៃកុមារ។ ការផ្តន្ទាទោសឱ្យជាក់លាក់ទៅលើអំពើល្បួង គឺមានការខ្វះចន្លោះនៅក្នុងច្បាប់នៃប្រទេសអនុវត្តគម្រោង ទាំងអស់ ហើយអនុសាសន៍មួយដែលសុំអោយមានការផ្តន្ទាទោសចំពោះអំពើល្បួង នឹងត្រូវដាក់ បញ្ចូលនៅក្នុងអនុសាសន៍នានា សម្រាប់ប្រទេសអនុវត្តគម្រោង។

មានភាពខ្វះចន្លោះគួរឱ្យកត់សម្គាល់មួយចំនួន នៅក្នុងកិច្ចការពារបច្ចុប្បន្ន ដែលមាននៅក្នុងប្រទេសកម្ពុជា ដើម្បីសម្របសម្រួលដល់ការចូលរួមរបស់កុមារក្នុងនាមជាជនរងគ្រោះ និងជាសាក្សីនៃអំពើកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ វិស័យនេះ តម្រូវឱ្យមានការពង្រឹងគួរឱ្យកត់សម្គាល់ ដើម្បីឱ្យមានភាពស្របគ្នាទៅនឹងកាតព្វកិច្ចអន្តរជាតិសំខាន់ៗ។ ជាពិសេស ខណៈពេលដែលលិខិតុបករណ៍ច្បាប់ និងគោលនយោបាយមួយចំនួនផ្តោតទៅលើបញ្ហានេះ ពុំមានលិខិតុបករណ៍ច្បាប់ និងគោលនយោបាយណាមួយ ដែលដោះស្រាយកម្រងនៃកិច្ចការពារគ្រប់ជ្រុងជ្រោយ ដែលពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារតម្រូវឱ្យអនុវត្ត ឬស្វែងរកធ្វើការសម្របសម្រួលឱ្យកុមារបាន ចូលរួមនៅក្នុងបរិបទជាក់លាក់ នៃបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារឡើយ ។ គេអាចធ្វើកំណែទម្រង់ ទៅលើវិស័យនេះតាមរយៈ ការពិនិត្យមើលបទប្បញ្ញត្តិ លិខិតុបករណ៍ គោលនយោបាយ ឬការច្របាច់បញ្ចូលគ្នានូវចំណុចទាំងពីរយ៉ាងនេះតែម្តង។

កម្មវិធីកំណែទម្រង់ច្បាប់សម្រាប់ប្រទេសកម្ពុជា គួរមានគោលបំណងអភិវឌ្ឍន៍ឱ្យមាននូវការឆ្លើយតបផ្លូវច្បាប់រឹងមាំមួយ ចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ ដោយប្រើប្រាស់បទដ្ឋានអន្តរជាតិជាចំណុចដៅ។ គេផ្តល់អនុសាសន៍ថា គោលដៅសកម្មភាពដើម្បីគាំទ្រដល់កំណែទម្រង់ច្បាប់នៅក្នុងប្រទេសកម្ពុជា គួរស្វែងរក ៖

**ការផ្តន្ទាទោស ៖ រូបភាពអាសអាភាសនៃកុមារ**

- គួរពិចារណាលើជម្រើសនានា ដើម្បីផ្តន្ទាទោសចំពោះអ្នករក្សាទុក រូបភាពអាសអាអាភាសនៃកុមារក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន
- គួរមានកំណត់ពន្យល់បំភ្លឺលម្អិតអំពី "ទីកន្លែងសាធារណៈ " ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ដើម្បីឱ្យការបកស្រាយច្បាប់ ទាក់ទង នឹងរូបភាពអាសអាភាសកុមារកាន់តែប្រសើរជាងមុន។

**ការផ្តន្ទាទោស ៖ ការរំលោភបំពានផ្លូវភេទ**

- គួរពិចារណាលើជម្រើសនានា ដើម្បីផ្តន្ទាទោសចំពោះការប្រព្រឹត្តណាដែលមនុស្សពេញវ័យល្បួងកុមារដើម្បីធ្វើការកេងប្រវ័ញ្ចផ្លូវភេទ។
- គួរបកស្រាយបទល្មើសឱ្យបានច្បាស់ក្រោមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ ជាពិសេសទាក់ទងនឹងការរំលោភបំពានផ្លូវភេទលើកុមារ និងពេស្យាចារលើកុមារ ដើម្បីធានាថាអាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរយុត្តិធម៌ យល់ដឹងច្បាស់ពីច្បាប់មួយណាដែលគួរតែយកមកអនុវត្តនៅក្នុងស្ថានភាពមួយដែលមិនមានវិសមិតភាពគ្នា។

*ការបកស្រាយច្បាប់*

- ធានាថា ទណ្ឌកម្មរដ្ឋបាល (ឧទាហរណ៍ ក្រោមច្បាប់ស្តីពីទេសចរណ៍) ពុំរាំងស្ទះដល់លទ្ធភាពរបស់អាជ្ញាធរអនុវត្តច្បាប់ ក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសឡើយ។

*វិធានការស្តីពីកិច្ចការពារកុមារ*

- អភិវឌ្ឍឱ្យមាននូវវិធានការគ្រប់ជ្រុងជ្រោយសម្រាប់ការពារសិទ្ធិ និងផលប្រយោជន៍កុមាររងគ្រោះ និងសាក្សីដើម្បីសម្របសម្រួលដល់ការចូលរួមរបស់ពួកគេនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលនិងគម្រោងស្តីពីកុមារភាព(ផ្នែកកិច្ចការពារ)ដើម្បីធានាថា អាជ្ញាធរអនុវត្តច្បាប់ជាអ្នកប្រើប្រាស់នីតិវិធី និងសម្ភារៈកុមារមេត្រី។

*កិច្ចសហប្រតិបត្តិការអន្តរជាតិ*

- យល់ព្រមថា ការផ្តល់សច្ចាប័ន អាចធ្វើទៅបានចំពោះបទល្មើសទាំងអស់ដែលទាក់ទងជាមួយទេសចរណ៍ផ្លូវភេទលើកុមារ បើទោះបីជាគ្មានកតិកាសញ្ញាក៏ដោយ និង
- កំណត់រកយន្តការសម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងធានាថា យន្តការទាំងនោះសម្របសម្រួលដល់ការផ្តល់វិធានការនៃការផ្តល់ជំនួយមួយដ៏ទូលំទូលាយ។

*ការស្នើសុំបន្ថែមៈ រដ្ឋាភិបាលកម្ពុជា*

បន្ថែមទៅលើអនុសាសន៍មួយចំនួនដែលបានរៀបរាប់ខាងលើ មន្ត្រីរដ្ឋាភិបាលកម្ពុជាបាន ឯកភាព កំណត់វិធានការបន្ត ដែលអាចពង្រឹងការឆ្លើយតបទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារៈ

- មជ្ឈមណ្ឌលកម្សាន្តរបស់មនុស្សពេញវ័យ ត្រូវមានផ្លាកសញ្ញាហាមមិនឱ្យកុមារចូល
- ក.ជ.ក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម សហការគ្នាក្នុងការវិភាគច្បាប់ស្តីពីកិច្ចការពារកុមារ និងច្បាប់ស្តីពីសុខុមាលភាព ដើម្បីបញ្ចូលបទប្បញ្ញត្តិច្បាប់ទាក់ទងនឹង ទេសចរណ៍ផ្លូវភេទលើកុមារ នៅពេលសេចក្តីព្រាងច្បាប់ នេះចាប់ផ្តើម
- បំភ្លឺពីទោសយោងតាមមាត្រា៦៨ នៃច្បាប់ស្តីពីទេសចរណ៍
- បទដ្ឋានក្រោមច្បាប់ទាក់ទងនឹងច្រកត្រួតពិនិត្យតាមព្រំដែន គួរពិនិត្យមើលឡើងវិញ ឬបង្កើតឱ្យមានដើម្បីធានាថា អ្នកទេសចរ និងអ្នកធ្វើដំណើរកម្សាន្តផ្លូវភេទ ត្រូវបានរកឃើញ និងមានវិធានការបន្ទាន់មុនពេលកុមារក្លាយជាជនរងគ្រោះនៃទេសចរណ៍ផ្លូវភេទ។ គួរពិចារណាឱ្យបានហ្មត់ចត់ផងដែរ ដើម្បីធានាថាវិស័យទេសចរណ៍មិនទទួលផលប៉ះពាល់ពីបទបញ្ញាខាងលើ ព្រោះទិដ្ឋាការត្រូវផ្តល់នៅនឹងកន្លែងឆែកឆេរ
- អនុក្រឹត្យស្តីពីមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ គួររៀបចំឡើងឱ្យបានលម្អិតដោយយោងតាមមាត្រា៥៦ និង៥៧ នៃច្បាប់ស្តីពីទេសចរណ៍
- គួររៀបចំឱ្យមានប្រកាសរួមរបស់ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ តាមលក្ខខណ្ឌតម្រូវដោយមាត្រា៦៣ នៃច្បាប់ស្តីពីទេសចរណ៍ ដើម្បីឱ្យមានការបែងចែក សមត្ថកិច្ចឱ្យបានច្បាស់រវាងនគរបាលទេសចរណ៍ និងមន្ត្រីអធិការកិច្ចទេសចរណ៍
- គួរពិនិត្យមើលឡើងវិញនូវច្បាប់ និងបទដ្ឋានក្រោមច្បាប់ការងារ ដើម្បីធានាថាកុមារ មិនធ្វើការនៅក្នុងមណ្ឌលកម្សាន្ត ដូចជាក្លិបរាត្រី ប៉ៀរហ្គាដិន បា ខារ៉ាអូខេ កន្លែងម៉ាស្សា។ល។

ដើម្បីសម្រេចនូវគោលបំណងនៃគម្រោងនេះ និងដើម្បីដំណើរការអនុសាសន៍ដែលបានរៀបរាប់នៅក្នុងផ្នែកនេះ រដ្ឋាភិបាលកម្ពុជាកំណត់សម្គាល់ថា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ និង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានការទទួលខុសត្រូវរៀងៗខ្លួន ក្នុងការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ក្នុងចំណោម កិច្ចការដទៃទៀតរបស់ខ្លួន។ គម្រោងនេះ អាចសម្រេចធ្វើសហប្រតិបត្តិការជាមួយរចនាសម្ព័ន្ធបច្ចុប្បន្ន នៃក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគ

ណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ) ទាក់ទងនឹងការអនុវត្តច្បាប់ និងការកសាងសមត្ថភាពជាមួយក្រសួងទេសចរណ៍ ទាក់ទងនឹងការបង្ការ ទេសចរណ៍ផ្លូវភេទលើកុមារ និង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារទាក់ទងនឹងការស្វែងរកការគាំទ្រមតិ និងការបង្កើតគោលនយោបាយ។

## ៦. ក្របខណ្ឌតំបន់

## ៦.១-កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែននៅក្នុងតំបន់

មានមូលដ្ឋានមួយដ៏រឹងមាំក្រោមសន្ធិសញ្ញាពហុភាគី សម្រាប់បណ្តាប្រទេសអនុវត្តន៍គម្រោងទាំងអស់ក្នុងការផ្តល់កិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យច្បាប់ ដើម្បីធ្វើការស៊ើបអង្កេត និង ការផ្តន្ទាទោសទៅលើបទល្មើសដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ ស្ថិតក្រោមបទដ្ឋាន ច្បាប់អន្តរជាតិ ប្រទេសអនុវត្តន៍គម្រោងនីមួយៗ តម្រូវឱ្យសម្របសម្រួលកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនសម្រាប់ការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ ចំពោះករណីដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ ក្នុងនាមជារដ្ឋភាគីរបស់ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម មានកាតព្វកិច្ចធានាឱ្យមាននូវវិធានការផ្តល់ជំនួយទូលំទូលាយបំផុតសម្រាប់ធ្វើការស៊ើបអង្កេត ផ្តន្ទាទោស និងធ្វើបត្យាប័ន សម្រាប់បទល្មើសកេងប្រវ័ញ្ចផ្លូវភេទលើកុមារ រាប់បញ្ចូលការប្រព្រឹត្តដែលជាធាតុផ្សំនៃទេសចរណ៍ផ្លូវភេទលើកុមារផងដែរ។ បន្ថែមពីនេះទៀត ក្នុងនាមជារដ្ឋភាគីនៃពិធីសារស្តីពីការជួញដូរមនុស្ស ប្រទេសកម្ពុជា និងប្រទេសឡាវ មានកាតព្វកិច្ចសម្របសម្រួលការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ទាក់ទងទៅនឹងបទល្មើសដែលត្រូវបានគូសបញ្ជាក់ ក្រោមពិធីសារស្តីពីការជួញដូរមនុស្ស ជាមួយរដ្ឋភាគីដទៃទៀត។ លក្ខខណ្ឌតម្រូវទាំងនេះ ដែលស្ថិតក្រោមពិធីសារជាជម្រើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារស្តីពីការជួញដូរមនុស្ស អាចយកមកអនុវត្តបាន មិនចំពោះថាតើរដ្ឋដែលធ្វើការស្នើសុំ និងរដ្ឋដែលត្រូវបានស្នើសុំ មាន ឬគ្មានទំនាក់ទំនងសន្ធិសញ្ញាទ្វេភាគីឡើយ។ បើទោះបីជាប្រទេសថៃ ពុំមែនជាភាគីនៃអនុសញ្ញាស្តីពីការជួញដូរមនុស្សក៏ដោយ ក្នុងនាមជាហត្ថលេខីមួយនៃលិខិតុបករណ៍នេះ ប្រទេសថៃត្រូវមានកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ដែលតម្រូវឱ្យចាត់វិធានការដែលអាចសម្រេចឱ្យបាន នូវកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញា[៨៥]។

ទំនាក់ទំនងសន្ធិសញ្ញាទ្វេភាគី ក៏ផ្តល់នូវវេទិកាមួយសម្រាប់កិច្ចសហប្រតិបត្តិការ រវាងបណ្តាប្រទេសអនុវត្តន៍គម្រោងផងដែរ ប៉ុន្តែកិច្ចសហប្រតិបត្តិការមិនចាំបាច់ត្រូវតែពឹងផ្អែកទៅលើវត្តមាននៃសន្ធិសញ្ញានោះទេ។ សន្ធិសញ្ញាទ្វេភាគី អាចផ្តល់នូវមូលដ្ឋានមួយដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិ

---

85 *អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា* (១៩៦៩)

ការ នៅក្នុងបញ្ហាព្រហ្មទណ្ឌ និងបញ្ជាក់ឱ្យបានច្បាស់លាស់ ព្រមទាំងសម្រួលដល់ដំណើរការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមករវាងប្រទេសអនុវត្តគម្រោង។ សន្ធិសញ្ញាទ្វេភាគីស្តីពីការធ្វើបត្យាប័នរវាងប្រទេសដៃគូអនុវត្តន៍គម្រោង បានចូលជាធរមានរវាងប្រទេសអនុវត្តគម្រោង[៨៦]។ គេក៏មានសន្ធិសញ្ញាតំបន់អាស៊ានមួយ ស្តីពីការផ្តល់ជំនួយទៅវិញទៅមកនៅ ក្នុងបញ្ហាព្រហ្មទណ្ឌផងដែរ ប៉ុន្តែពុំមែនសមាជិកទាំងអស់របស់អាស៊ាន សុទ្ធសឹងតែបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញានេះឡើយ[៨៧]។ ពុំមានព័ត៌មានស្តីពីប្រតិបត្តិការ និងប្រសិទ្ធ ភាពនៃសន្ធិសញ្ញាទាំងនេះឡើយ។

កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់មិនផ្លូវការ ក៏ជាឧបករណ៍មួយដ៏សំខាន់ផងដែរ ក្នុងការប្រយុទ្ធ ប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ កិច្ចសហប្រតិបត្តិការមិនផ្លូវការដែលត្រូវបានគេហៅថាជា "ការផ្តល់ជំនួយរវាងនគរបាល" ឬ "ការផ្តល់ជំនួយរវាងភ្នាក់ងារ" ផងដែរនោះ មិនតម្រូវឱ្យមានមូលដ្ឋានច្បាប់ឡើយ និងអាចសម្របសម្រួលឱ្យមាននូវវិធានការទូលំទូលាយមួយសម្រាប់ចែករំលែកព័ត៌មានរវាងភ្នាក់ងារអនុវត្តន៍ច្បាប់បឋមនៃប្រទេសផ្សេងៗគ្នា។ កិច្ចសហប្រតិបត្តិការមិនផ្លូវការ អនុញ្ញាតឱ្យនគរបាល ចែករំលែកព័ត៌មានចារកម្ម ដែលទាក់ទងទៅនឹងការអនុវត្តច្បាប់ (ឧទាហរណ៍ ប្រវត្តិរបស់ជនល្មើស និង កំណត់ហេតុនៃការធ្វើដំណើររបស់ជនល្មើស) ក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត ខណៈពេលដែលគេកំពុងប្រមូលភស្តុតាងនៅឡើយ។ កិច្ចសហប្រតិបត្តិការមិនផ្លូវការ សម្របសម្រួលឱ្យមាននូវ លំហូរព័ត៌មានឆាប់រហ័ស និងអាចមានសារៈប្រយោជន៍ក្នុងការកំណត់អត្តសញ្ញាណ ថាតើអាចមានភស្តុតាង នៅក្នុងយុត្តាធិការដទៃទៀត និងកំណត់ថាតើគេចាំបាច់តម្រូវឱ្យមានដំណើរការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកជាផ្លូវការដែរឬទេ។

សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់មិនផ្លូវការ ត្រូវបានគូសបញ្ជាក់នៅក្នុងរបាយ-ការណ៍នេះ អាស្រ័យដោយវាមានទំនាក់ទំនងជិតស្និទ្ធទៅនឹងយន្តការនៃការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកជាផ្លូវការ។ បើទោះជាដូច្នេះក្តី ពុំមានព័ត៌មានអំពីរយៈពេល និងប្រសិទ្ធភាពនៃបណ្តាញមិនផ្លូវការសម្រាប់ការផ្តល់ជំនួយឡើយ។ ដូចត្រូវបានគូស បញ្ជាក់ខាងដើមនៅក្នុងរបាយការណ៍នេះ ខណៈពេលដែល INTERPOL កំពុងធ្វើការងារជាមួយភ្នាក់ងារអនុវត្តន៍ច្បាប់ក្រោមសសរស្តម្ភផ្នែកកិច្ចការពារ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេ ក្នុងការស៊ើបអង្កេត និងសហប្រតិបត្តិការនៅក្នុងករណីទេសចរណ៍ផ្លូវភេទលើកុមារ។ របាយការណ៍នេះនឹងផ្តោតយកចិត្តទុកដាក់ចំពោះតែក្របខណ្ឌច្បាប់ជាផ្លូវការ ដែលតម្រូវឱ្យមានសម្រាប់ កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែនប៉ុណ្ណោះ។

---

[86] *សន្ធិសញ្ញារវាងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្រកម្ពុជាស្តីពីការធ្វើបត្យាប័ន (១៩៩៩) សន្ធិសញ្ញារវាងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យ និងប្រទេសថៃស្តីពីការធ្វើបត្យាប័ន (១៩៩៩)*

[87] *សន្ធិសញ្ញាអាស៊ានស្តីពីការផ្តល់ជំនួយផ្នែកច្បាប់ទ្វេភាគី នៅក្នុងបញ្ហាព្រហ្មទណ្ឌ (២០០៤)*

## ៦.២. កិច្ចខិតខំសហប្រតិបត្តិការកម្រិតតំបន់កាន់តែទូលំទូលាយ

ពុំមានលិខិតុបករណ៍ណាមួយ ដែលដោះស្រាយឱ្យបានជាក់លាក់ចំពោះបញ្ហាកិច្ចសហប្រតិបត្តិការតំបន់ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារឡើយ។ នេះគឺជាភាពខ្វះចន្លោះ មួយគួរឱ្យកត់សម្គាល់នៅក្នុងក្របខណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសដ៏ទៃទៀតក្នុងតំបន់។

ក្របខណ្ឌតំបន់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិលើផ្នែកច្បាប់ នៅក្នុងវិស័យដទៃទៀត ដែល មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា ផ្តល់នូវបរិបទមួយដ៏មានសារៈប្រយោជន៍ដែលអាចពង្រឹងបន្ថែមដើម្បី លើកកម្ពស់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន នៅក្នុងករណីទេសចរណ៍ផ្លូវភេទលើកុមារ។ ឧទាហរណ៍ *អនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិ ការប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ* (២០០៤) ត្រូវបានអភិវឌ្ឍក្រោមការគាំទ្រពីការសម្របសម្រួលផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រទេសតំបន់ទន្លេមេគង្គ ប្រឆាំងទៅនឹងការជួញដូរ (COMMIT MOU) បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រដ្ឋ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរ[៨៨]។ ក្នុងលក្ខណៈមួយដែលកាន់តែទូលំទូលាយជាងមុន សមាគមប្រជា-ជាតិអាស៊ីអាគ្នេយ៍ (ASEAN) បានយល់ព្រមទប់ស្កាត់អំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ច តាមរយៈទេសចរណ៍ ក្រោម*កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន* (២០០២) និងសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស ក្រោម*សេចក្តីថ្លែងការណ៍អាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ* (២០០៤)។ កិច្ចព្រមព្រៀងទ្វេភាគីរវាងប្រទេសជាដៃគូ ក៏បានបង្កើតឱ្យមាននូវការប្តេជ្ញាចិត្តមួយ ដើម្បីធ្វើសហប្រតិបត្តិការ សំដៅប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស បើទោះបីជាកិច្ចព្រមព្រៀងទាំងនោះ ពុំមានលក្ខណៈជាការចងកាតព្វកិច្ចតាមផ្លូវច្បាប់ក៏ដោយ។ កិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់រវាងកម្ពុជានិងវៀតណាម កម្ពុជានិងថៃ សុទ្ធសឹងតែបាន ពង្រឹងចំពោះកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន បានកាន់តែប្រសើរជាងមុននៅក្នុងបញ្ហាជួញដូរ មនុស្ស។ លិខិតុបករណ៍ដែលមានលក្ខណៈទូលំទូលាយជាងមុនទាំងនេះ អាចជួយផ្តល់ការណែនាំ ដល់កិច្ចខិតខំក្នុងការពង្រឹងក្របខណ្ឌ សម្រាប់កិច្ចសហប្រតិ-បត្តិការថ្នាក់តំបន់ ដើម្បីផ្តោតគោលដៅ ទៅលើកម្រងនៃបទល្មើសដែលមានលក្ខណៈទូលំទូលាយជាងនេះ បើទោះជាដូច្នេះក្តី លិខិតុបករណ៍ ទាំងនេះ ផ្តល់ការណែនាំបន្តិចបន្តួចប៉ុណ្ណោះសម្រាប់កិច្ចសហប្រតិបត្តិការ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។

---

[88] p3

# ៦.៣. សង្ខេប និងអនុសាសន៍

ដើម្បីធានាថា កិច្ចខិតខំថ្នាក់តំបន់មានលក្ខណៈស្របទៅនឹងបទដ្ឋានអន្តរជាតិសំខាន់ៗ និងសម្រួលឱ្យមាននូវការសម្របសម្រួលឆ្លងកាត់ព្រំដែន ដើម្បីឆ្លើយតបទៅនឹងបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ។ គេផ្តល់អនុសាសន៍ថា ត្រូវអនុវត្តសកម្មភាពតាមតំបន់ ដែលផ្តោតយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍក្របខណ្ឌការងារ ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការ (ឧទាហរណ៍ តាមរយៈលិខិតុបករណ៍ដែលមិនចងកាតព្វកិច្ច) សម្របសម្រួលដល់ការចែករំលែកព័ត៌មានអំពីបញ្ហាច្បាប់សំខាន់ៗ និងអភិវឌ្ឍបណ្តាញការងារកម្រិតមន្ត្រីទទួលបន្ទុក។ គេផ្តល់អនុសាសន៍ថា សកម្មភាពជំនួយបច្ចេកទេស គួរផ្តោតយកចិត្តទុកដាក់ទៅលើកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ៖

- កំណត់ថាតើទំនាក់ទំនងសន្ធិសញ្ញាដែលមានស្រាប់ (ក្រោមក្របខណ្ឌពហុភាគី ក្របខណ្ឌតំបន់ និងក្របខណ្ឌទ្វេភាគី) ផ្តល់នូវមូលដ្ឋានមួយដែលគ្រប់គ្រាន់ សម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសអនុវត្តន៍គម្រោងដែរឬទេ (តាមរយៈការធ្វើបត្យាប័ន និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក) និងក្នុងករណីចាំបាច់ត្រូវស្នើឱ្យមាននូវការអភិវឌ្ឍក្របខណ្ឌសន្ធិសញ្ញាបន្ថែម
- ផ្តល់វេទិកាមួយសម្រាប់អភិវឌ្ឍលិខិតុបករណ៍ថ្នាក់តំបន់ (ដែលពុំមានការចងកាតព្វកិច្ច ដូចជាអនុស្សរណៈនៃការយោគយល់) ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនថ្នាក់តំបន់នៅក្នុងការឆ្លើយតបយុត្តិធម៌ព្រហ្មទណ្ឌចំពោះបញ្ហាទេសចរណ៍ផ្លូវភេទកុមារ
- ពិនិត្យស្វែងរកឱកាសដើម្បីរៀបចំបង្កើតឱ្យមាននូវលិខិតុបករណ៍ទ្វេភាគី (ដែលពុំមានការចងកាតព្វកិច្ច ដូចជាអនុស្សរណៈនៃការយោគយល់) ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការទ្វេភាគីនៅក្នុងករណីទេសចរណ៍ផ្លូវភេទលើកុមារ
- ផ្តល់ឱកាសដើម្បីពិភាក្សាអំពីអាទិភាពរួមសម្រាប់កំណែទម្រង់ច្បាប់ និងដើម្បីបង្កើនសក្តានុពលជាអតិបរមា សម្រាប់ការធ្វើសុខដុមនីយកម្មនៃបទល្មើសព្រហ្មទណ្ឌដែលផ្តោតគោលដៅទៅលើទេសចរណ៍ផ្លូវភេទលើកុមារ និង
- សម្របសម្រួលដល់ការចែករំលែកព័ត៌មាន រវាងប្រទេសអនុវត្តន៍គម្រោងអំពីកិច្ចសហប្រតិបត្តិការ ឆ្លងកាត់ព្រំដែន នៅក្នុងករណីទេសចរណ៍ផ្លូវភេទលើកុមារ រាប់បញ្ចូលឱកាសក្នុងការកសាងបណ្តាញកម្រិតមន្ត្រីទទួលបន្ទុក សំដៅពង្រឹងទំនាក់ទំនងការងារ និងបង្កើនលទ្ធផលនៃករណីជាអតិបរមា។

## ៧-ផែនការអនុវត្តន៍

ការសហការធ្វើការងារជាមួយប្រទេសជាដៃគូ ដើម្បីពង្រឹងក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយស្របតាមបទដ្ឋានអន្តរជាតិ និងនីតិរដ្ឋ គឺជាជំហានមួយដ៏សំខាន់សំដៅធានាថា ជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ មិនអាចគេចផុតពីការផ្តន្ទាទោស និងអាចត្រូវបាននាំខ្លួនទៅកាន់តុលាការបានឆាប់រហ័ស។ ការអនុវត្តកម្មវិធីមួយដែលមានគោលដៅ និងបំណងធានានិរន្តរភាពនៃជំនួយបច្ចេកទេសផ្នែកច្បាប់ ដើម្បីដោះស្រាយបញ្ហានៃភាពខ្វះចន្លោះនៃច្បាប់ និងពង្រឹងសមត្ថភាពរបស់ស្ថាប័នច្បាប់ និងស្ថាប័នយុត្តិធម៌ គឺជាគន្លឹះក្នុងការសម្រេចឱ្យបាននូវគោលបំណងរបស់គម្រោងស្តីពីកុមារភាព (ផ្នែកកិច្ចការពារ) ព្រមទាំងជាចំណុចស្នូលដើម្បីធានាថា បណ្តាប្រទេសនៃមហាអនុតំបន់ទន្លេមេគង្គ មានឧបករណ៍ស្របច្បាប់ ដើម្បីស៊ើបអង្កេត និងផ្តន្ទាទោសទៅលើជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ។

ដោយមានបទដ្ឋានច្បាប់អន្តរជាតិសំខាន់ៗជាចំណុចដៅ យើងដឹងថា ក្របខណ្ឌច្បាប់ប្រកបដោយប្រសិទ្ធភាពដើម្បីប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ តម្រូវឱ្យមាន ៖

- ការផ្តន្ទាទោសគ្រប់ជ្រុងជ្រោយទៅលើការប្រព្រឹត្តដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ
- ទោសប្បញ្ញត្តិតឹងរឹងដែលឆ្លុះបញ្ចាំងអំពីភាពធ្ងន់ធ្ងរនៃបទល្មើស
- វិធានការស្តីពីកិច្ចការពារកុមារ សម្រាប់ជនរងគ្រោះ និងសាក្សី នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និង
- ក្របខណ្ឌការងារ សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់។

របាយការណ៍នេះ ផ្តល់នូវការប៉ាន់ប្រមាណជាមូលដ្ឋានមួយនៅប្រទេសកម្ពុជា (នៅក្នុងបរិបទក្របខណ្ឌថ្នាក់តំបន់ និងប្រទេសអនុវត្តគម្រោងដទៃទៀតដូចជា ប្រទេសឡាវ ថៃ និងវៀតណាម)។ ការស្រាវជ្រាវបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា បទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា ពុំទាន់មានភាព គ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ ឱ្យបានសមស្របនៅឡើយទេ។ ច្បាប់ បង្ហាញពីភាពខ្វះចន្លោះគួរកត់សម្គាល់មួយចំនួន ដែលធ្វើឱ្យស្ថាប័នច្បាប់ និងស្ថាប័នយុត្តិធម៌ប្រឈម ទៅនឹងភាព

ប្រថុយប្រថាន ដោយការប្រព្រឹត្តបទល្មើសជាប្រចាំ និងដដែលៗ ព្រមទាំងធ្វើឱ្យកុមារមានភាពងាយរងគ្រោះទៅនឹងការកេងប្រវ័ញ្ច។ របាយការណ៍នេះ បានស្នើនូវវិស័យសំខាន់ៗមួយចំនួន ដែលត្រូវបានផ្តល់អនុសាសន៍សម្រាប់ ការផ្តោតយកចិត្តទុកដាក់ នៃកិច្ចខិតខំកំណែ ទម្រង់ច្បាប់ក៏ដោយ ក៏គេនៅតែតម្រូវឱ្យអនុវត្តន៍ ការងារបន្ថែមទៀត ក្រោមភាពជាដៃគូជាមួយរដ្ឋាភិបាលកម្ពុជា និងអ្នក ពាក់ព័ន្ធដទៃទៀត ដើម្បីកែលម្អបន្ថែមទៀតទៅលើសំណើសម្រាប់ការធ្វើកំណែទម្រង់ច្បាប់ ដើម្បីកំណត់ព្រំដែននៃសកម្មភាពជំនួយបច្ចេកទេសច្បាប់ កំណត់អាទិភាពរួមរវាង UNODC និងប្រទេសកម្ពុជា និងកសាងភាពជាម្ចាស់ ព្រមទាំងធានាឱ្យមាននូវការប្តេជ្ញាចិត្តពីរដ្ឋាភិបាលកម្ពុជា។

ផែនការអនុវត្តន៍ខាងក្រោម ផ្តល់នូវក្របខណ្ឌការងារមួយ ដើម្បីអនុវត្តសកម្មភាពជំនួយបច្ចេកទេសផ្នែកច្បាប់ជាមួយប្រទេសកម្ពុជា (នៅក្នុងបរិបទនៃក្របខណ្ឌថ្នាក់តំបន់ និងបណ្តាប្រទេសអនុវត្តគម្រោងដទៃទៀត)។ ខណៈពេលដែលសកម្មភាពជាក់លាក់នានា នឹងមានភាពខុសប្លែកពីគ្នាដោយផ្អែកទៅលើសេចក្តីត្រូវការ និងអាទិភាពដែលត្រូវបានកំណត់រកឃើញ (និងធម្មជាតិជាក់លាក់នៃជំនួយបច្ចេកទេសដែលបានស្នើសុំ) ផែនការអាចត្រូវបានគេយកមកប្រើប្រាស់ជាគំរូមួយ ដើម្បីផ្តល់ការណែនាំទៅលើសកម្មភាពទាំងនោះ។ ផែនការអនុញ្ញាតឱ្យមានភាពបត់បែន ដើម្បីឱ្យគេអាចធ្វើការកែសម្រួលទៅលើសកម្មភាពបានតាមកម្មវិធីវិវត្តទៅមុខ។ ក្នុងករណីដែលកម្មវិធីត្រូវបានកែលម្អ និងមានភាពប្រសើរឡើងជាលំដាប់ គេអាចអភិវឌ្ឍផែនការអនុវត្តន៍កាន់តែច្បាស់លាស់ជាក់លាក់។

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br><br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| ការអភិវឌ្ឍផែនការគម្រោង ក្រោមភាពជាដៃគូជាមួយ សមភាគីភ្នាក់ងាររដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត | ប្រើប្រាស់ជំនាញឯកទេសនៅក្នុងប្រទេស លើបញ្ហាច្បាប់សំខាន់ៗ ជាពិសេសការ កំណត់រកវិស័យសំខាន់ៗ សម្រាប់ធ្វើ កំណែទម្រង់ច្បាប់ និងការយល់ដឹងអំពី លក្ខខណ្ឌតម្រូវដើម្បីអនុវត្តច្បាប់ ជាក់ស្តែងប្រកបដោយប្រសិទ្ធភាព។<br><br>កំណត់អាទិភាពរបស់ប្រទេសកម្ពុជា សម្រាប់ធ្វើកំណែទម្រង់ច្បាប់។ | ▪ ការត្រៀមឯកសារពិភាក្សាអំពីប្រទេសអនុវត្តន៍គម្រោងនីមួយៗ ដោយគូសបញ្ជាក់អំពីភាពខ្វះចន្លោះនៃបទប្បញ្ញត្តិ ដែលត្រូវបានកំណត់រកឃើញ (និងភាពខ្វះចន្លោះ គោលនយោបាយក្នុងករណីសមស្រប) ដើម្បីបង្ហាញនៅក្នុងសិក្ខាសាលាស្តីអំពីច្បាប់ *[សកម្មភាពនេះ អាចដកស្រង់យកសម្ភារមួយចំនួនដែលត្រូវបានរៀបចំនៅក្នុងរបាយការណ៍នេះ ប៉ុន្តែត្រូវអភិវឌ្ឍនឱ្យបានជាក់លាក់ សម្រាប់ប្រទេសដែលអនុវត្តគម្រោង និងគូសបញ្ជាក់អំពីបញ្ហាជាក់លាក់ដែលត្រូវពិភាក្សាជាមួយអ្នកពាក់ព័ន្ធ]*។<br><br>▪ ការបកប្រែ និងការចែកចាយឯកសារពិភាក្សាជូនដល់សមភាគីរ | *ឆ្នាំទី១ ៖ ២០១១/១២*<br><br>*[កញ្ញា ២០១១-សីហា ២០១២]*<br><br>ទីប្រឹក្សាច្បាប់អន្តរជាតិ |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | វាស់ស្ទង់ទៅលើការប្តេជ្ញាចិត្តរបស់ ប្រទេសកម្ពុជា សម្រាប់សំណើរសកម្មភាព ជំនួយបច្ចេកទេសផ្នែកច្បាប់។ | រដ្ឋាភិបាលដើម្បីពិចារណា<br>▪ ការបង្ហាញអំពីគំហើញរបាយការណ៍ច្បាប់ ដែលមានលក្ខណៈជាក់លាក់ចំពោះប្រទេសនីមួយៗ (ដោយប្រើប្រាស់ឯកសារគោលដៅសម្រាប់ការពិភាក្សា) នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ<br>▪ ការរៀបចំក្រុមបេសកកម្ម ដើម្បីជួបជាមួយសមភាគីរដ្ឋាភិបាលសំខាន់ៗ (និងអ្នកពាក់ព័ន្ធដទៃទៀត ដែលសម ស្រប) ៖ កិច្ចសម្ភាសន៍ និងការពិភាក្សាដើម្បីកំណត់រកបញ្ហាច្បាប់ សំខាន់ៗមួយចំនួន ស្វែងយល់អំពីលក្ខខណ្ឌតម្រូវទូទៅ សម្រាប់ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងធ្វើការប៉ាន់ប្រមាណអំពីតំរូវការរបស់ប្រទេសជាដៃគូ<br>▪ ការអភិវឌ្ឍផែនការគម្រោងឱ្យបានគ្រប់ជ្រុងជ្រោយ ស្របទៅ | មន្ត្រីគម្រោងថ្នាក់ជាតិ<br><br>ទីប្រឹក្សាច្បាប់អន្តរជាតិ |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | | តាមស្ថានភាពរបស់ប្រទេសអនុវត្តន៍គម្រោងនីមួយៗ ដែលឆ្លុះបញ្ចាំងអំពីលទ្ធផលនៃកិច្ចពិភាក្សាអំពីវិសាលភាពនៃបេសកកម្ម ដោយដាក់បញ្ចូលការប៉ាន់ប្រមាណទៅបទប្បញ្ញត្តិ និងការកំណត់រកបញ្ហាច្បាប់ជារូបវ័ន្ត (និងបញ្ហាគោល នយោបាយ ក្នុងករណីសមស្រប) ដើម្បីយកមកធ្វើការដោះស្រាយ ដោយរាប់បញ្ចូលអនុសាសន៍ជាក់លាក់មួយចំនួនផងដែរ<br>▪ ការបកប្រែ និងការចែកចាយផែនការគម្រោងគោលដៅជូនដល់សមភាគីរដ្ឋាភិបាល ដើម្បីពិចារណា។ | ទីប្រឹក្សាច្បាប់ជាតិ<br>*[គាំទ្រដោយក្រុម កិច្ចការពារ]* |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | | | ទីប្រឹក្សាច្បាប់ជាតិ<br>*[គាំទ្រដោយក្រុម កិច្ចការពារ]* |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤ | | | |
|---|---|---|---|
| ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | | | មន្ត្រីគម្រោងថ្នាក់ជាតិ |
| សិក្ខាសាលា និងការប្រមូលព័ត៌មានពីបណ្ដាដៃគូរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត | កសាងសមត្ថភាព និងការយល់ដឹងនៅ ក្នុងប្រទេសអំពីកាតព្វកិច្ចច្បាប់អន្តរជាតិ សំខាន់ៗ។<br><br>ពិភាក្សាអំពីវិស័យសំខាន់ៗដែលត្រូវបាន ស្នើឡើងសម្រាប់ការធ្វើកំណែទម្រង់ច្បាប់ និងទទួលបានព័ត៌មានអំពីបរិបទក្នុងប្រទេស។<br><br>ជំរុញឱ្យមានការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល | ▪ សិក្ខាសាលាស្តីពីច្បាប់ ជាមួយមន្ត្រីរដ្ឋាភិបាលសំខាន់ៗ ដើម្បីពិភាក្សាអំពីសំណើកំណែទម្រង់<br><br>▪ បង្កើតក្រុមការងារមួយ ជាមួយសមភាគីរដ្ឋាភិបាល (និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងករណីសមស្រប) ដែលមានភារកិច្ចអភិវឌ្ឍន៍កំណែទម្រង់ច្បាប់។ ករណីមានរចនាសម្ព័ន្ធជាធរមានស្រាប់ដែលមានប្រសិទ្ធិភាព ផ្សារភ្ជាប់គម្រោងជាមួយរចនាសម្ព័ន្ធនោះ ក្នុងការអនុវត្តគម្រោង។ | *ឆ្នាំទី១ ៖ ២០១១/១២*<br><br>ក្រសួងយុត្តិធម៌<br><br>*[គាំទ្រដោយ ក្រុមគម្រោងផ្នែកកិច្ចការពារ]* |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ផាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ផាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ផាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | ទាំងមូល (និងក្នុងករណីសមស្របត្រូវជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល) ចំពោះសំណើកំណែទម្រង់ច្បាប់។ | | |
| ការអភិវឌ្ឍបទប្បញ្ញត្តិ<br><br>*[សំគាល់ ៖ ក្នុងករណីសមស្រប ការអភិវឌ្ឍឯកសារគោល-នយោបាយ ក៏អាចស្ថិតក្រោមសកម្មភាពនេះផងដែរ]* | រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ ក្រោមភាព ជាដៃគូជាមួយសមភាគីរដ្ឋាភិបាល។ | ▪ UNODC ផ្តល់ជំនួយបច្ចេកទេសជូនដល់ក្រុមការងារ ឬរចនា សម្ព័ន្ធជាធរមាន ដើម្បីរៀបចំសេចក្តីព្រាងសំណើបទប្បញ្ញត្តិ<br>▪ ជម្រើសមួយទៀតគឺជួយរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារ ឬសុខុមាលភាពកុមារ។ សេចក្តីព្រាងនេះអាចដាក់បញ្ចូលជំពូកធំមួយដែលមានបញ្ញត្តិពីទេសចរណ៍ផ្លូវភេទលើកុមារ ក្នុងចំណោមបទប្បញ្ញត្តិផ្សេងៗទៀត<br>▪ កិច្ចប្រជុំក្រុមការងារទៀងទាត់ ដើម្បីពិភាក្សាអំពីសេចក្តីព្រាង | *ឆ្នាំទី២ ៖ ២០១២/១៣*<br>ក្រសួងយុត្តិធម៌<br>មន្ត្រីសម្របសម្រួលគម្រោង<br>មន្ត្រីគម្រោងជាតិ |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br><br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | | បទប្បញ្ញត្តិ<br><br>▪ កែសម្រួលទៅលើសេចក្តីព្រាងបទប្បញ្ញត្តិទៅតាមមតិយោបល់របស់ក្រុមការងារ<br><br>▪ សេចក្តីព្រាងចុងក្រោយត្រូវបានបញ្ចប់រួចរាល់ និងទទួលបានការឯកភាពពីក្រុមការងារ<br><br>▪ បញ្ចប់សេចក្តីព្រាងច្បាប់នៅថ្នាក់ក្រសួង(ឆ្នាំទី២និងទី៣) | ទីប្រឹក្សាច្បាប់ជាតិ<br><br>*[គាំទ្រដោយ ក្រុមគម្រោងផ្នែកកិច្ចការពារ]* |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ផាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ផាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ផាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| ពង្រឹងសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ក្នុងវិស័យ ធ្វើដំណើរ និងទេសចរណ៍ | ស្វែងរក និងលើកស្ទួយសហប្រតិបត្តិការ អន្តរជាតិ ជាពិសេស តាមបណ្តា ភ្នាក់ងារ អនុវត្តច្បាប់ និង បណ្តាប្រទេសក្នុងតំបន់ (តាមរយៈអនុស្សារណៈនៃការយោគយល់គ្នា ប្រសិនបើចាំបាច់) | ▪ ផ្តល់ជំនួយបច្ចេកទេស និងជំនួយផ្សេងទៀតតាមការចាំបាច់ ដើម្បីលើកស្ទួយសហប្រតិបត្តិការអន្តរជាតិ<br>▪ ធ្វើការប្រជុំទៀងទាត់ លើប្រធានបទទេសចរណ៍ផ្លូវភេលើកុមារ | *ក្រុមគម្រោងផ្នែកកិច្ចការពារនគរបាល និង ក្រសួងយុត្តិធម៌*<br>*ឆ្នាំទី១៖ ២០១១/ ១២*<br>*ឆ្នាំទី២៖ ២០១២/ ១៣ ឆ្នាំទី៣ ៖ ២០១៣/ ១៤* |
| ការបណ្តុះបណ្តាល និងការ លើកកម្ពស់ការយល់ដឹង | ពង្រឹងសមត្ថភាពរបស់ភ្នាក់ងារអនុវត្តន៍ច្បាប់ ក្នុងប្រទេស ដើម្បីឱ្យពួកគេយល់ អាចមានលទ្ធ | ▪ រៀបចំបង្កើត និងធ្វើតេស្តសាកល្បងសម្ភារបណ្តុះបណ្តាល<br>▪ ការផ្តល់សិក្ខាសាលាបណ្តុះបណ្តាល ៖ ផ្តោតលើនគរបាល ព្រះ | *ឆ្នាំទី២ ៖ ២០១២/១៣* |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | ភាពបកស្រាយ និងអនុវត្តបទប្បញ្ញត្តិច្បាប់ថ្មីៗ។<br><br>លើកកម្ពស់ការយល់ដឹង និងផ្ដល់កិច្ច គាំទ្រជូនដល់ភ្នាក់ងាររដ្ឋាភិបាល និង ភ្នាក់ងារមិនមែនរដ្ឋាភិបាល អំពីបញ្ហា កំណែទម្រង់ច្បាប់។ | រាជអាជ្ញា និងប្រព័ន្ធតុលាការ។ | *ឆ្នាំទី៣ ៖ ២០១៣/១៤*<br>ក្រុមគម្រោងផ្នែកកិច្ចការពារ<br>*[គាំទ្រដោយទីប្រឹក្សាច្បាប់អន្តរជាតិ និងទីប្រឹក្សាច្បាប់ជាតិ]* |
| សន្និសីទថ្នាក់តំបន់ ស្ដីពីការពង្រឹងក្របខណ្ឌច្បាប់ ដើម្បីប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ | សម្របសម្រួលដល់ការចែករំលែកព័ត៌មានរវាងប្រទេសអនុវត្តន៍គម្រោងអំពីកម្មវិធី កំណែទម្រង់ច្បាប់។ | ▪ រៀបចំសន្និសីទថ្នាក់តំបន់រួមគ្នាជាមួយប្រទេសអនុវត្តន៍គម្រោង (ត្រូវរៀបចំនៅពេលចាប់ផ្ដើម ពាក់កណ្ដាល និងចុងបញ្ចប់ នៃគម្រោង) | *ឆ្នាំទី១ ៖ ២០១១/១២*<br>*ឆ្នាំទី២ ៖ ២០១២/១៣* |

## ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤

<u>ធាតុចេញ ១</u>៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ

<u>ធាតុចូល ១.១</u> ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង <u>ធាតុចូល ១. ២</u>៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ

| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
|---|---|---|---|
| នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ | ជំរុញឱ្យមាននូវបណ្តាញឆ្លងកាត់ព្រំដែន រវាងភ្នាក់ងារច្បាប់ និងភ្នាក់ងារយុត្តិធម៌ នៅក្នុងប្រទេសដៃគូ។<br><br>បង្កើនសក្តានុពលសម្រាប់ការធ្វើសុខដុម នីយកម្មនៃបទល្មើសព្រហ្មទណ្ឌ ដែលផ្តោតគោលដៅទៅលើទេសចរណ៍ផ្លូវភេទលើកុមារ នៅក្នុងតំបន់។<br><br>ផ្តល់វេទិកាសម្រាប់អភិវឌ្ឍលិខិតុបករណ៍ | ▪ ការអភិវឌ្ឍលិខិតុបករណ៍ថ្នាក់តំបន់ (ពុំមានការចងកាតព្វកិច្ចតាមផ្លូវច្បាប់) ដើម្បីសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ | *ឆ្នាំទី៣ ៖ ២០១៣/១៤*<br><br>*[ផ្សព្វផ្សាយនៅក្នុងរយៈពេល គម្រោងទាំងមូល]*<br><br>ក្រុមកិច្ចការពារ<br><br>ទីប្រឹក្សាច្បាប់អន្តរជាតិ |

| ផែនការអនុវត្តន៍គម្រោង ៖ ២០១១-២០១៤<br>ធាតុចេញ ១៖ ការពង្រឹង និងជំរុញក្របខណ្ឌច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ<br>ធាតុចូល ១.១ ៖ ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ធាតុចូល ១. ២៖ អនុសាសន៍ច្បាស់លាស់ និងជាក់លាក់ ត្រូវបានដាក់ជូនរដ្ឋាភិបាលជាដៃគូ ដើម្បីជំរុញក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងជនល្មើសទេសចរណ៍ផ្លូវភេទលើកុមារ | | | |
|---|---|---|---|
| គោលដៅ | គោលបំណង | សកម្មភាព | រយៈពេល និងសកម្មភាព |
| | កម្រិតថ្នាក់តំបន់ (ពុំមានការចងកាតព្វកិច្ចតាមផ្លូវច្បាប់) ដើម្បីសម្របសម្រួលដល់កិច្ច សហប្រតិបត្តិការឆ្លងកាត់ព្រំដែន និងបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ប្រទេសដៃគូ ក្នុងការលើកកម្ពស់ឱ្យមាននូវការឆ្លើយតបយុត្តិធម៌ព្រហ្មទណ្ឌរួមគ្នាចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារ។ | | ទីប្រឹក្សាច្បាប់ជាតិ |

UNODC

United Nations Office on Drugs and Crime

**Regional Office for Southeast Asia and the Pacific**
United Nations Building, 3rd floor B Block, Secretariat Building, Raj Damnern Nok Avenue, Bangkok 10200, Thailand
Tel. (66-2) 288-2091 Fax. (66-2) 281-2129 E-mail: fo.thailand@unodc.org
Website: http://www.unodc.org/southeastasiaandpacific